ឆ្នាំទី ៤ ថ្ងៃទី ១

លេខ ៨ ខែសីហា

ទស្សនាវដ្តី

# កម្ពុជសុរិយា

ផ្សាយចេញ

សាសនា, អក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ

ព.ស. ២៤៩៧ ចេញរាល់ថ្ងៃទី១ខែ

គ.ស. ១៩៥៤ ប្រក្រតិទិនសុរិយគតិ



នេះគឺអនាគារិកធម្មបាលទេវាសត ជាតិលង្កា

រោងពុម្ព ពាក លេខ ១១១ វិថីព្រែកតោ ភ្នំពេញ

# មាតិការឿង


| | | | |
|---|---|---|---|
| បណ្ណាធិការ | ម៉ៅ-មៀម | ........................ វិចារណកថា | ទំព័រ ១ |
| | | ........................ លិខិត ឯ.ឧ. នាយករដ្ឋមន្ត្រីនិង ឯ.ឧ. ស៊ោ-ហ៊ុ | " ២ |
| លោក | ស៊ុង-ប៊ាង | ........................ បដិបទានៃសន្តិភាព | " ៣ |
| លោក | ចាប-ពិន | ........................ ពិធីបញ្ចុះបឋមសិលា (ត) | " ៦ |
| | | ........................ សន្និសីទ (ត) | " ១២ |
| មហា | គួច-គីឡេង | ........................ ដំណើរពីជម្ពូទ្វីប | " ១៥ |
| ព្រះពុទ្ធវង្ស | ភៅ-ស៊ុម | ........................ ពិធីបុណ្យបញ្ចុះអដ្ឋធាតុនិងសីមា | " ២៦ |
| | | ........................ ការជ្រួតជ្រាបចិត្តចំពោះពុទ្ធសាសនា | " ៣០ |
| | | ........................ ប្រវត្តិនៃក្មេងកំព្រា | " ៣២ |


## សូមលោកអ្នកអានកុំភ្លេច!

មុននឹងលោក-អ្នក បើកទំព័រទស្សនាវដ្ដីនេះអានសូមនឹកកុំភ្លេចថា ប្រទេសយើងបានឯករាជ្យដោយសន្តិវិធី ជាស្នាព្រះហស្តនៃព្រះប្រមុខមហាក្សត្ររបស់យើង; កាលបើយើងនឹកដល់ហេតុនេះ ក៏គួរនឹកដល់បេះដូងរបស់ឯករាជ្យផង តើនៅត្រង់ណា?

មែនឬទេ? យើងខ្ញុំថាសាសនាប្រចាំរដ្ឋជាតួបេះដូង! បើដូច្នេះត្រូវយើងបបួលគ្នាជ្រោមជ្រែងសាសនាយើងឲ្យរឹងដំហរឡើង កុំឲ្យរាប់អានឬរលាយទៅតាមលទ្ធិណាមួយ ។

– ចុះវិធីដូចម្ដេចដែលគួរឲ្យយើងរក្សាបាន?

-គួរទទួលស្គាល់សមាគមមិត្តសាលាបាលី ដោយសទ្ធាចិត្ត ឬក៏បានជាវ "ទស្សនាវដ្ដីមិត្តសាលាបាលី" ដែលផ្សាយចេញពីសមាគមនេះ ដោយរួសរាន់ បើយើងស្រុះស្រួលគ្នាជួយសមាគមនេះ ដោយវិធីណាមួយ យើងនឹងឃើញពន្លឺនៃការចំរើនយ៉ាងឆាប់រហ័សតាំងពីពេលនេះទៅ! ពន្លឺអ្វី? ឯករាជ្យដែលមានសាសនាជាបេះដូង! ។

---

អ្នកទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោកម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ ។

**adresse :** *Monsieur* **Mao-Mey** *Ministère de l'intérieur P. Penh*

R.44-10-54



# តើសង្គ្រាមលោកស្ងប់មែនឬ?

ក្នុងថ្ងៃទី២០កក្កដា គឺជាទិវាសួស្តីប្រកបដោយឧត្តមឫក្ស យ៉ាងប្រសើរបំផុត ដែលពិភពលោកក្រោកឈរទះដៃគ្រប់គ្នា ហើយស្រែកថាជយោ! សន្តិភាព!!! ព្រោះថ្ងៃនោះជាពេលដែលមហាសន្និបាតនៅហ្សឺណែវ បានយល់ព្រមរំលត់ភ្លើងសង្គ្រាមនៅឥណ្ឌូចិន ដោយការមូលមតិគ្នាជាឯកច្ឆន្ទ ។

អ្នកប្រតិភូដំណាងប្រទេសនានា ទោះបីប្រទេសកាន់លទ្ធិរួមសម្បាច់ ឬកាន់លទ្ធិប្រជាធិបតេយ្យក៏ដោយ តែងមានទឹកមុខស្រស់ស្រាយទៅកាន់គ្នាជានិច្ច មានការទុបរឹតសំដែងសេចក្តីស្មោះស្ម័គ្រ ដល់គ្នានិងគ្នាដោយមេត្រីភាពយ៉ាងក្រៃលែង ចំពោះជ័យជំនះដែលទើបនឹងដណ្តើមយកបាន នៅទីមហាសន្និបាតនោះ ។ គេចាំបានថាក្នុងកំឡុងដែលសន្និសីទកំពុងតែប្រព្រឹត្តទៅ, មានការបង្ហូរឈាមរវាងជាតិអ្នកឥណ្ឌូចិនយ៉ាងមហាសាហាវ ដែលធ្វើឲ្យសន្និសីទរឹតតែរំភើបរំជួយខ្លាំងឡើង ។ ពេនសាពតិមានខ្វះទឹកអាណិតអាសូរដល់ជនអ្នករងគ្រោះខ្លាំងនោះខ្លាំង ពេកក៏បែរជាស្រែកឡើងថា "បើមហាសន្និបាតនៅហ្សឺណែវ មិនបានការទេ គំគួរតែបំបែកសម័យប្រជុំចោលទៅ" ខ្លះក៏ស្រែកសុំឲ្យមហាសន្និបាតរិះរកមធ្យោបាយយ៉ាងរហ័សបំផុត ដើម្បីបំបាត់សង្គ្រាមនៅឥណ្ឌូចិន; ដូចជាកាលពីខែឧសភាមុននេះ វិចារណកថារបស់ទស្សនាវដ្តីយើង ក៏បានអំពាវនាវឲ្យមហាសន្និបាតចុះសម្រុងគ្នាដោយរួសរាន់ ដើម្បីរកសន្តិភាពដែរ ព្រោះពួកយើងជាអ្នកសាសនា មានការរន្ធត់ខ្លាំងណាស់ចំពោះការប្រហារជីវិតគ្នាឥតត្រាប្រណីដូចនោះ ដោយពួកយើងជាអ្នកមានមធ្យោបាយតែមួយ គឺមិនចង់ជួបប្រទះការប្រហារគ្នារវាងមនុស្សជាតិក្នុងលោក ដែលជាគ្រឿងធ្វើសត្វលោកឲ្យវិនាសគ្មានហេតុផល, ត្រូវការស្វែងរកតែមិត្តដែលមិនបះពាល់ទែងគ្នា បេះឲ្យសេចក្តីសុខដល់គ្នានិងគ្នាប៉ុណ្ណោះ ។

ឥឡូវនេះថ្ងៃ២០ កក្កដា បានហុចពន្លឺសុខសន្តិភាពដល់ពិភពលោកហើយ ប្រហែលជាយើងលែងបានជួបប្រទះអំពើអធម្មកម្មបែបនោះទៀត ឬក៏ដូចម្តេចទៅវិញ......

យើងសូមអំពាវនាវដល់ជនអ្នកស្វែងរកសន្តិភាពក្នុងលោក ដែលមានបំណងស្របនឹងពួកយើង ដើម្បីព្រួតដៃគ្នារក្សាសន្តិភាពនេះ ឲ្យគង់វង្ស ។ ព្រោះថាបើតាមក្បួនក្នុងសាសនា ដែលយើងបានសិក្សាពីទេវព្រះសម្ពុទ្ធមកអាចឲ្យមើលឃើញដោយបញ្ញាចក្ខុថា "ភ្លើងដែលកំពុងតែឆេះផ្ទះមួយធំ លុះត្រូវទឹកភ្លៀងច្រើនគ្រប់សង្កត់ខ្លាំង ក៏រលត់ភ្លាមមួយរំពេច តែចំណែករងើកភ្លើង ដែលក្រោមចុះទៅផ្ទាល់នឹងផែនដី

ដោយមានច្បួសជាច្រើនសង្កត់ពីលើពុំទាន់អស់អង្កាច់(១) ភ្លើងនៅឡើយ អង្កាច់ភ្លើងនេះហើយដែលអាចបង្កបានភ្លាមមិនយឺតយូរបើយើងមិនបានចាក់ទឹកឲ្យត្រជាក់ដល់ផែនដីទេ" ដែលយើងហ៊ានពោលដូចនេះព្រោះពុទ្ធភាសិតសំដែងថា "សេចក្ដីសុខ កើតពីសាមគ្គីធម៌" តើសព្វថ្ងៃពិភពលោកបិតនៅក្នុងសាមគ្គីធម៌ ហើយឬនៅ?

ដូចនេះគួរយើងប្រុងប្រយ័ត្នឲ្យមែនទែន វត្ថុស័ក្តិសិទ្ធិយើងចាប់យកបានហើយ កុំឲ្យវត្ថុនោះអន្តរធានបាត់ទៅវិញ! ខ្ញុំខ្លាចណាស់ត្រង់ពុទ្ធដីកាថា វិប្បដិសារី បានសេចក្ដីថា ស្ដាយក្រោយ!

## ជយោ ! សន្តិភាពពិភពលោក

---

ឯកឧត្ដមនាយករដ្ឋមន្ត្រីនិងឯកឧត្ដម ង៉ោ-ហូ រដ្ឋមន្ត្រីក្រសួងការពារប្រទេសបានចូលជាសមាជិកកិត្តិយសក្នុងនាមនៃសមាគមមិត្តសាលាបាលី ។

យើងសូមចុះចុតហ្មាយរបស់ ឯកឧត្ដម ទាំងពីរ ដែលឆ្លើយតបចំពោះលោកអធិបតីសមាគមយើងទាំងស្រុងដោយឥតកែប្រែដូចតទៅ :

ព្រះរាជអាណាចក្រកម្ពុជា

ទីស្ដីការនាយករដ្ឋមន្ត្រី

លេខ ៣១៥ ន.រ.ម ល.ជ.

ក្រុងភ្នំពេញ ថ្ងៃ ៣១ ខែកក្កដា គ.ស. ១៩៥៤

## អ្នកឧកញ៉ា នាយករដ្ឋមន្ត្រី

ជំពាបមក លោក ក៉យ-ប៊ុក អធិបតីសមាគមមិត្តសាលាបាលី

បានជ្រាប ។

តបសំបុត្រលោកលេខ ៧០ ចុះថ្ងៃ ១៩ ខែកក្កដា គ.ស. ១៩៥៤ ដែលបានជូននូវនាមមន្តលសមាជិកកិត្តិយសចំពោះអ្នកឧកញ៉ា តាមសេចក្ដីព្រមព្រៀងពីក្រុមអភិបាលសមាគមមិត្តបាលីនោះ ។

អ្នកឧកញ៉ាសុំទទួលនូវនាមសមាជិកកិត្តិយស នេះដោយសោមនស្ស ហើយសុំជូនសេចក្ដីអំណរយ៉ាងជ្រាលជ្រៅដល់លោកនិងក្រុមសមាគមមិត្តសាលាបាលីដោយស្មោះស្ម័គ្រ ។

សុំលោកទទួលនូវសេចក្ដីមេត្រីភាពរបស់ខ្ញុំដោយខ្ពង់ខ្ពស់ ។

ប៉ែន-នុត

---

(១) អង្កាច់ = កំទេចភ្លើងតូច ៗ ដែលនៅសល់ ឬ កំទេចឈើល្អិត ៗ ដែលគេយកមកបង្កាត់ភ្លើងឲ្យឆេះឡើង(ពាក្យនេះសូមវិនិច្ឆ័យចំពោះលោកវិញផង)

ភ្នំពេញ, ថ្ងៃទី ៣១ ខែកក្កដា គ.ស. ១៩៥៤

គ្រូពេទ្យវះសេនីឯក ង៉ោ-ហ៊ូ នាយកស្ដីទីនៃអគ្គសេនាធិការខេមរយោធា សូមតបដំណឹងមកលោកអធិបតីនៃសមាគមមិត្តសាលាបាលីនៅភ្នំពេញ

សូមជ្រាប ។

លោកអធិបតី,

ដោយបានទទួលលិខិតរបស់លោកមួយច្បាប់ លេខ ៧០ ចុះថ្ងៃទី ១៩ ខែកក្កដា គ.ស. ១៩៥៤ ដោយមានសេចក្ដីស្នើសុំឲ្យខ្ញុំទទួលព្រមធ្វើជាសមាជិកកិត្តិយស នៃសមាគមមិត្តសាលាបាលីនោះ ខ្ញុំសូមជម្រាបលោកថា ខ្ញុំយល់ព្រមទទួលនាមមង្គលនេះ ដោយសេចក្ដីសោមនស្សយ៉ាងស្មោះស្ម័គ្រ ព្រោះខ្ញុំតែងមានសមានចិត្តចំពោះសមាគមនេះ ជាយូរអង្វែងមកហើយដែរ ។

សូមលោកទទួលនូវសេចក្ដីរាប់អានពីខ្ញុំដ៏ស្មោះ

ង៉ោ-ហ៊ូ

# បដិបទានៃសន្តិភាព

ការចងមេត្រីផ្សាយសេចក្ដីសុខទាំងបំពេញគុណធម៌គឺសេចក្ដីល្អត្រង់ចំពួកចំពោះគ្នានឹងគ្នា ជាផ្លូវការពារនូវការបៀតបៀនទាំងឡាយ ៗ យើងគប្បីប្រើវិធីធ្វើសត្រូវឲ្យក្លាយទៅជាមិត្រ ដោយសេចក្ដីល្អយ៉ាងពិតប្រាកដក្នុងចិត្តរបស់យើង ។

អ្នកដែលគិតត្រឹមតែសើស្បែកគង់ឃើញថា ត្រង់គោលធម៌នៃព្រះពុទ្ធសាសនា ដែលប្រដៅឲ្យផ្ចាញ់មនុស្សដោយសេចក្ដីល្អនោះ គឺជាការប្រៀនប្រដៅឲ្យទន់ខ្សោយឲ្យជាមនុស្សកំសាកញី មិនតែប៉ុណ្ណោះ ថែមទាំងឲ្យមានមេត្តាករុណាចំពោះជនជាសត្រូវទៀតផង, បើមនុស្សយើងប្រតិបត្តិតាម តើស្រុកទេសនឹងតាំងនៅដូចម្ដេចបាន នឹងមិនធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃរបស់សត្រូវហើយឬ? ព្រោះការសម្លាប់សត្រូវក៏ឈ្មោះថាធ្វើបាបដូចគ្នា បើយើងខ្លាចបាបមានតែយើងសុខចិត្តធ្វើជាទាសៈគេ មិនមែនឬ? បញ្ហានេះខ្ញុំយល់ឃើញថា យើងគួរគិតគួរនិយាយនឹងគួរនាំគ្នាត្រិះរិះរកហេតុផលឲ្យឃើញស-ទៅ ព្រោះក្នុងសាសនារបស់យើងឥតមានការទាស់ខុសចំពោះការនិយាយប្រកួតប្រកាំងគ្នា ដើម្បីរកសេចក្ដីពិតទេ ។

តាមយោបល់របស់ខ្ញុំថា គោលធម៌របស់ព្រះពុទ្ធសាសនាត្រង់ខនេះជ្រាលជ្រៅណាស់ ត្រាតែអ្នកដែលពិចារណាត្រឹមតែសើ ៗ យល់ឃើញថា "ខុស" ហាក់ដូចជាប្រាប់ថា ការប្រតិបត្តិតាមគោលធម៌នេះ ប៉ុនគ្នានឹងហាត់ធ្វើខ្លួនឲ្យជាមនុស្សទន់ទាប ដែលជាហេតុនាំឲ្យមនុស្សដទៃមើលងាយ ឬក៏ហែងកំញើញជារឿយ ៗ បានតាមចិត្ត ៗ តែបើពិចារណាមើលឲ្យជ្រាលជ្រៅសុខុមទៅហើយ ក៏អាចនឹងឃើញច្បាស់

ថា "គោលធម៌នេះ ពុំមែនបង្ហាត់បង្រៀនខ្លួនឲ្យ ទៅជាមនុស្សកំសាកញ្ញីទេ គឺធ្វើឲ្យទៅជាមនុស្ស មិនចាញ់គេ ព្រោះមិនត្រូវច្បាំងនឹងនរណា ធ្វើឲ្យជា មនុស្សមិនមានសត្រូវ ព្រោះមិនបណ្ដុះពូជសត្រូវ, ធម៌កែខែដល់ដើមហេតុ កាត់ដើមហេតុនៃសេចក្ដីក្ដៅ ក្រហាយតាំងមូលឲ្យសាបសូន្យ ការកែខចុងហេតុ ពោលគឺការបង្អង់ចាំឲ្យសត្រូវញាំញីហើយសិន ទើប តស៊ូនោះ រមែងតែមានចាញ់ខ្លះ ឈ្នះខ្លះ ស្មើគ្នាខ្លះ តែទោះបើចាញ់ឬឈ្នះឬស្មើគ្នាក៏ដោយ ការវិនាស អន្តរាយ ក៏រមែងកើតមានឡើងដល់គូតស៊ូទាំងសង ខាងជានិច្ច ទើបលោកប្រៀបថា ដូចជាបាចរបស់ ស្ទាគគ្រោគផាក់គ្នានឹងគ្នា មុខជាប្រឡាក់ស្អុយអ- សោចដូចគ្នាទាំងសងខាងពុំខាន ។ កាលបើគោល ធម៌នៃព្រះពុទ្ធសាសនាកែខមិនឲ្យកើតបាចសាច របស់ស្ទាកគ្រោកផាក់គ្នា មិនឲ្យច្បាំងគ្នានឹងឲ្យមាន មេត្តាករុណាអាណិតអាសូរចំពោះគ្នានឹងគ្នាយ៉ាងនេះ តើមិនចាត់ព្រះពុទ្ធសាសនាថាបង្ហាត់ឲ្យទៅជាមនុស្ស ទន់ខ្សោយដូចម្ដេចបាន ? បើយើងល្បងពិចារណាមើល ចុះថា ការដែលយើងប្រដៅគ្នាឲ្យប្រើទឹកសម្រាប់ លត់ភ្លើង ជំនួសប្រើប្រេងសម្រាប់លត់នោះ តើ ជាការប្រដៅដ៏ត្រឹមត្រូវឬទេ? ហើយដើម្បីឲ្យរឹតតែ ច្បាស់យើងត្រូវពិចារណាតទៅទៀតថា ការដែល យើងប្រដៅគ្នាឲ្យបេះការពារ កុំឲ្យភ្លើងឆេះឡើងបាន ដែលជាហេតុធ្វើឲ្យយើងមិនបាច់ទៅក្ដៅក្រហាយខ្វល់ ខ្វាយក្នុងការលត់នោះ ជាការល្អឬបេះជាងការ ប្រដៅឲ្យយកប្រេងលត់ភ្លើងយ៉ាងណាខ្លះ? ការ ដែលយើងសង្ស័យថា "ការសម្លាប់សត្រូវ ចាត់ជា បាបឬទេ" នោះប្រែថា "យើងទៅផ្សារភ្ជិតតែចុង ហេតុប៉ុណ្ណោះ" គឺយើងបង្អង់ចាំឲ្យកើតសត្រូវ ហើយទើបគិតកែខជាខាងក្រោយ, ត្រង់នេះ ហាក់ ដូចជាយើងបង្អង់ឲ្យភ្លើងឆេះហើយទើបរកវិធីលត់ ។ ព្រះពុទ្ធសាសនាបានប្រៀនប្រដៅតាំងវិធីការពារ មិន ឲ្យភ្លើងឆេះ គឺមិនឲ្យកើតសត្រូវ តាំងវិធីលត់ភ្លើង ដោយត្រូវទំនង គឺកាលបើសត្រូវកើតឡើងហើយ ត្រូវឲ្យដឹងវិធីកែខឲ្យសមគួរ កុំទៅបន្ថែមសត្រូវឲ្យ ច្រើនឡើងទៀត ត្រូវឲ្យបេះវិធីរលស់សត្រូវឲ្យតិចចុះ មកដោយប្រើសេចក្ដីល្អតបទៅវិញ ត្រង់នេះលោក ប្រៀបថាដូចជារលស់កម្ដៅភ្លើងដោយទឹក ឬដោយ វត្ថុដែលមិនមែនជាពូជនៃភ្លើងដទៃ ៗ ទៀតមានកក់ជា ដើម ។

ខ្ញុំសូមស្រង់យកនិទានមកជូនអស់លោក - អ្នក ស្ដាប់ត្រឹម១រឿង ដែលជារឿងគួរគិតនាំឲ្យកើតប្រ- យោជន៍ច្រើនជាងការដែលយើងពិចារណាថា ពិតឬ ទេគួរជឿឬទេនោះតទៅ ៖

ក្នុងអតីតកាល មានទេវាល័យដ៏សក្ដិសិទ្ធិ១កន្លែង តាំងនៅត្រង់រវាងព្រំប្រទល់នៃដែនកុរុនឹងបញ្ចាលៈ ។ ក្សត្រតាំង ២ អង្គនៃ ដែនទាំងពីរនោះជាសត្រូវគូអា ឃាតនឹងគ្នាបេះតែនាំគ្នាលើកកងទ័ពច្បាំងលុកទន្ទ្រាន

ដណ្ដើមយកអាណាខេត្តនៃគ្នានឹងគ្នាជាដរាបមក ដូចកាលម្ចាស់ចាញ់ដូចកាលម្ចាស់ឈ្នះប្ដូរឈ្នះជាប់ត ៗ គ្នា ខ្លះក៏មានចាញ់ ហើយចាញ់ទៀតក៏មាន កាលបើមានឱកាសល្មមនឹងច្បាំងគ្នាបាន ក៏ចេះតែច្បាំងគ្នាទៅ ព្រោះហេតុនោះក្នុងខណៈដែលទំនេរចំបាំងម្ដង ១ ដោយខាងម្ចាស់ចាញ់នោះ ក៏ប៉ុនគ្នានឹងឈប់សម្រាកយកកម្លាំងដើម្បីត្រៀមខ្លួនប្រុងប្រៀប ធ្វើសង្គ្រាមកែសម្ពីចិត្តរបស់ផ្នែកខាងចាញ់ ៗ ក្នុងទេវាល័យនោះមានទេវតាដែលមានស័ក្តិធំឋិតនៅ ; ទេព្ដានោះមានអាយុយឺនយូររាប់តាំងពាន់ ៗ ឆ្នាំកន្លងមកហើយ ធ្លាប់សំដែងសេចក្ដីសក្ដិសិទ្ធិឲ្យប្រាកដ ដល់ពួកមនុស្សទើបជាទីនិយមរាប់អានគោរពកោតក្រែង របស់មនុស្សទូទៅ កាលបើក្សត្រខាងណាមានកម្លាំងហើយលើកកងទ័ពចូលទៅរុករានខាងម្ចាស់ទៀតមុននឹងហួសពីទេវាល័យនោះទៅ តែងតែចូលទៅធ្វើគារវៈបន់ស្រន់ នឹងបូជាទេវតានោះសិនមិនដែលដាច់ ៗ ទេព្ដាដែលនៅក្នុងទេវាល័យនោះ បានឃើញរឿងរ៉ាវនៃការធ្វើសង្គ្រាមរវាងដែនទាំង ២ រាល់តែលើកដែរ ប៉ុន្តែចេះតែអត់សង្កត់ចិត្ត ដាក់ជាឧបេក្ខាព្រងើយ ១ បណ្ដោយឲ្យប្រព្រឹត្តទៅតាមកម្មរបស់សត្វដែលក្រហល់ក្រហាយក្ដៅស្អុះពុះឈាមសម្លាប់គ្នាដោយមានចិត្តងងឹតងងល់រហូតមក ៗ

សម័យ ១ កាលក្សត្រទាំង២ខាង មកប្រទល់គ្នាត្រង់ជាយដែននោះ ទេព្ដាដែលធ្លាប់តែអត់ទ្រាំព្រងើយ ៗជាច្រើនជួរអាយុមនុស្សមកហើយនោះ ឃើញថាពេលនេះគួរនឹងប្រដៅពួកមនុស្សទាំងនោះ ឲ្យដឹងច្បាស់នូវសេចក្ដីវើរវាយក្នុងការធ្វើសង្គ្រាមរបស់ខ្លួន ហើយឲ្យកើតសេចក្ដីតក់ស្លុតចិត្ត ដឹងសេចក្ដីវិនាសច្បាស់លាស់ប្រាកដទើបលោកសំដែងកាយឲ្យប្រាកដអណ្ដែតនៅកណ្ដាលអាកាស ពោលប្រកាសដល់ក្សត្រមេទ័ពមេកងនិងពលទាហានទាំង២ផ្នែកដោយសំឡេងយ៉ាងខ្លាំងថា ៖

ឱមនុស្សទាំងអស់គ្នា! យើងនេះគឺជាទេព្ដាដែលឋិតនៅក្នុងទេវាល័យ ដែលពួកអ្នកទាំងឡាយធ្លាប់គោរពបូជានុះ, យើងបានអត់ទ្រាំមើលពួកអ្នកធ្វើសង្គ្រាមនឹងគ្នា ជាច្រើនជួរអាយុមនុស្សមកហើយ យើងដឹងថាពួកអ្នកគឺនរណា ហើយនរណាខ្លះដែលវិលកើតវិលស្លាប់ច្បាំងគ្នានៅទីនេះៗ នៃក្សត្រនិងពលនិកាយនៃដែនកុរុ អ្នកទាំងឡាយដឹងឬទេថា "គ្រាខ្លះពួកអ្នកទៅកើតជាអ្នកបញ្ចាលៈ ហើយលើកទ័ពមកច្បាំងដណ្ដើមយកដែនកុរុ ដែលអ្នកកើតអាស្រ័យក្នុងជាតិនេះ" ៗ ឱ!ក្សត្រនិងពលនិកាយនៃដែនបញ្ចាលៈ អ្នកទាំងអស់ដឹងឬទេថា ជាច្រើនគ្រាមកហើយដែលពួកអ្នកទៅកើតក្នុងដែនកុរុ ហើយលើកទ័ពមកវាយយកបញ្ចាលៈរបស់ខ្លួនឯងដែល" ៗ ពួកអ្នកទាំងអស់គ្នា វិលកើតវិលស្លាប់ក្នុងដែននុះខ្លះ នេះខ្លះ ហើយក៏លើកទ័ពមកសម្លាប់តែគ្នាឯងយ៉ាងងងឹតក្នុកដោយគ្រាន់តែធ្វើឲ្យបំណងរបស់ខ្លួនក្នុងជាតិបច្ចុប្បន្ននេះបាន

សម្រេចផលប៉ុណ្ណោះ តែស្រេចហើយក្នុងជាតិតទៅ អ្នកទាំងអស់គ៏ទៅកើតក្នុងដែនខាងម្ខាងវិញ ហើយ លើកទ័ពមកកៃដម្លឹខាងផ្នែកខ្លួនឯងដដែល ជាដដែល ថែមទាំងធ្វើទារុណកម្ម ចំពោះកូនចៅពូជពង្សវង្ស ត្រកូលរបស់ខ្លួនឯងទៀត ។ អ្នកទាំងសងខាងបាន កែខៃដម្លឹខ្លួនឯងដដែលៗ ទាំងច្បាំងលុកទន្ទ្រាន តែគ្នាឯងដដែលៗ យ៉ាងកោលាហលដូច្នេះប៉ុន្មាន លើកប៉ុន្មានគ្រាមក ហើយជារឿងគួរឲ្យសង្វេគ តក់ស្លុតយ៉ាងក្រៃលែង ។ យើងសូមឲ្យអ្នកទាំងសង ខាងយល់ឲ្យច្បាស់ក្នុងរឿងដែលមានពិតនេះចុះហើយ ចូរលើកលែងច្បាំងគ្នា តាំងអំពីពេលនេះជាដើមទៅ ចូរបណ្ដុះមេត្រីចិត្តចំពោះគ្នានឹងគ្នា ជួយអើពើអាណិត អាសូរគ្នា កាលបើយ៉ាងនេះអ្នកទាំងអស់គ្នាក៏នឹងមាន តែសេចក្ដីសុខដូចគ្នាទាំងសងខាង ។

មនុស្សទាំង២ដែននោះ បានទទួលសេចក្ដីតក់ស្លុតក្នុងចិត្ត នាំគ្នាលើកលែងច្បាំងហើយក៏ផ្សាសម្ពន្ធមិត្តមេត្រីចិត្តចំពោះគ្នានឹងគ្នារហូតមក ព្រោះអាស្រ័យទេព្ដាអង្គនោះ ដែលយើងសូមសន្មតនាមថា សន្តិទេវបុត្រ ។

ស៊ុន - ហ៊ាន

## ពិធីបញ្ចុះសិលាចារិកនៅស្ថាបនាវិទ្យាល័យ ព្រះសីហនុរាជ(ត)

សូមព្រះតេជះដំកល់លើត្បូង សូមព្រះរាជទាន ក្រាបបង្គំទូលព្រះករុណាជាម្ចាស់ជីវិត សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ឱកាសនេះ ទូលព្រះបង្គំជាខ្ញុំ សូមសំដែងនូវមនោភាពសម្បយុត្ត ដោយសោមនស្ស ចេតនានឹងបីតិប្រាមោជដ៏ក្រៃលែង ចំពោះព្រះករុណា ជាម្ចាស់ជីវិតលើត្បូង ចំពោះសម្ដេច, លោកអ្នកម៉ុ-ស៊ិរ ឯកឧត្តម នាយករដ្ឋមន្ត្រីនឹងរដ្ឋមន្ត្រីទាំងឡាយ ព្រមទាំងទ្រង់ នឹងឯកឧត្តមជាអគ្គទូតដែលបានស្ដេច យាង និមន្ត អញ្ជើញមកជួបជុំជាមហាសន្និបាតក្នុង ឱកាសពិធីបុណ្យបញ្ចុះបឋមសិលានេះ ព្រោះមហា សន្និបាតដែលប្រកបដោយឥស្សរជនគ្រប់ប្រភេទ មាន ព្រះករុណាជាម្ចាស់ជីវិតលើត្បូងជាប្រធានដូច្នេះទុកជា កិត្តិយសមួយដ៏ប្រសើរ នឹងជាមង្គលសួស្ដីមួយដ៏ឧត្តម សមដល់កិច្ចការដែលទាក់ទងនឹងព្រះពុទ្ធសាសនា ជាទីគោរពរបស់ប្រជាជនក្នុងប្រទេស ។

សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានឱកាសបន្តិច ដើម្បីថ្លែងរៀបរាប់ ដោយសង្ខេបនូវមូលហេតុ នៃការកសាងគ្រឹស្ថាន នៃមហាវិទ្យាល័យនេះដូចតទៅ ៖

ការសិក្សាខាងព្រះពុទ្ធសាសនា ក្នុងប្រទេស កម្ពុជានេះ បានកើតឡើងតាំងពីឆ្នាំ ១៩១៤ ដរាប

ដល់សព្វថ្ងៃនេះ ៤០ ឆ្នាំហើយ កន្លែងនៃការសិក្សានោះ គឺសាលាបាលីជាន់ខ្ពស់នេះឯង ជាសាលាតែមួយ ស្ថិតនៅក្នុងសេចក្ដីឧបត្ថម្ភរបស់ព្រះរាជរដ្ឋាភិបាល ។ ឯសាលាបាលីរង បានកើតមានឡើងតាំងពីឆ្នាំ ១៩៣៣ សាលានេះឋិតនៅក្នុងសេចក្ដីឧបត្ថម្ភរបស់លោកចៅអធិការវត្ត ព្រមទាំងពុទ្ធបរិស័ទជើងវត្ត ឯរាជការគ្រាន់តែទទួលស្គាល់ហើយនិងជួយចាត់ការឲ្យមានរបៀបរៀនសូត្រ និងការប្រឡងចេញពីសាលាប៉ុណ្ណោះ ។ សាលាបាលីរងនោះ តាំងពីកើតឡើង២១ឆ្នាំហើយ រួមទាំងក្នុងក្រុងនិងខេត្តក្រៅ សព្វថ្ងៃនេះមានចំនួន៣៥១សាលាហើយ ។ បព្វជិតដែលសិក្សាក្នុងសាលាបាលីរងបានគ្រប់ ៣ ឆ្នាំ ត្រូវប្រឡងចេញ បានទទួលវិញ្ញាបនប័ត្រ១ជាសំគាល់របស់លោកដែលបានវិញ្ញាបនប័ត្រទាំងនោះ ត្រូវមានអំណាចមកប្រឡងចូលរៀនក្នុងសាលាបាលីជាន់ខ្ពស់ សព្វថ្ងៃនេះកាន់តែច្រើនឡើង ៗ ដូចក្នុងឆ្នាំ ១៩៥៣ និង ១៩៥៤ នេះ ឃើញមានបព្វជិតចំនួន ២០០០ រូបមកប្រឡងយកកន្លែងរៀនក្នុងសាលាបាលីជាន់ខ្ពស់ដែលមានតែ ១០០ កន្លែង ឃើញត្រូវនៅសល់ ១៩០០រូប ។

សាលាបាលីជាន់ខ្ពស់សព្វថ្ងៃនេះ ពុំអាចនឹងចាត់ការឲ្យបានចំរើនជាងនេះទៅទៀត ព្រោះខ្វះទីកន្លែងរៀន ខ្វះគ្រូបង្រៀន ។ សព្វថ្ងៃនេះពួកបព្វជិតដែលរៀនសូត្របានត្រឹមតែវិញ្ញាបនប័ត្រ ក្នុងសាលាបាលីរងកាន់តែមានច្រើនឡើង ៗ រកច្រកផ្លូវចេញទៅណាមិនរួចក៏សឹកខ្លះនៅសល់ខ្លះបំរុងនឹងប្រឡងតទៅទៀត សូម្បីពួកបព្វជិតដែលបានចូលមកសិក្សា ក្នុងសាលាបាលីជាន់ខ្ពស់គ្រប់ ៤ ឆ្នាំហើយប្រឡងចេញ បានទទួលសញ្ញាប័ត្រពីសាលានេះហើយក៏ដោយ សិស្សទាំងនោះក៏មានចំណេះចេះដឹងមិនទាន់ដល់ទីបំផុតនៅឡើយ ព្រោះការសិក្សា ៤ ឆ្នាំបានតែត្រឹមមធ្យមសិក្សាប៉ុណ្ណោះ ឃើញថានៅខ្វះខាតចំណេះវិជ្ជាជាច្រើនណាស់ ប៉ុន្តែសិស្សទាំងនោះឥតមានកន្លែងនឹងសិក្សាតទៅទៀតទាល់មុខទាល់ក្រោយ ក៏សឹកចេញទៅរកចិញ្ចឹមជីវិតតាមធម្មតាខ្លះ ប្រកបការងារក្នុងរាជ-ការខ្លះ ដែលសល់នៅក្នុងភេទបព្វជិតតិចតួចស្ដួចស្ដើង លោកណាមានឧស្សាហ៍ខ្លាំង ក៏ប្រឹងចេញពីប្រទេសកម្ពុជាទៅសិក្សានៅប្រទេសក្រៅ ដោយកម្លាំងរបស់ខ្លួន និងដោយទ្រព្យធនរបស់មាតាបិតាខ្លួន ។ ការទៅបំពេញចំណេះវិជ្ជាយ៉ាងនេះ ក៏មិនមានច្រើនប៉ុន្មាន មានបន្តិចបន្តួចហើយច្រើនតែមិនត្រឡប់មកកាន់មាតុ-ភូមិវិញ ដែលសល់នៅក្នុងប្រទេសខ្លះ ក៏សុទ្ធតែមានចំណេះវិជ្ជាមិនគ្រប់គ្រាន់ ព្រោះគ្មានកន្លែងសិក្សាតទៅទៀត ម្ល៉ោះហើយពួកបព្វជិតក្នុងប្រទេសក៏ឋិតនៅក្នុងឋានៈជាអ្នកមានចំណេះទន់ខ្សោយ ហើយព្រះពុទ្ធសាសនាក៏ទន់ខ្សោយទៅតាមដែរ ។

ក្នុងបច្ចុប្បន្នកាលនេះ ប្រទេសទាំងឡាយក្នុងលោក ដែលកាន់ព្រះពុទ្ធសាសនាកំពុងតែចំរើនបណ្ដុះបណ្ដាលពួកបព្វជិត ឲ្យមានចំណេះវិជ្ជាច្រើនឡើង គឺឲ្យបានចេះចំណេះក្នុងព្រះពុទ្ធសាសនាទាំងខាងវិជ្ជាផ្លូវលោកព្រមទាំងភាសាបរទេសឲ្យចេះគ្រប់គ្រាន់ ប្រយោជន៍នឹងឲ្យបព្វជិតទាំងនោះបានបំពេញកិច្ចក្នុងព្រះពុទ្ធសាសនាសម្រាប់ប្រទេស ឲ្យចំរើនរុងរឿងឡើងផង ឲ្យមានសមត្ថភាពអាចនឹងពង្រីកព្រះពុទ្ធសាសនាឲ្យរីកធំទូលាយឡើងផង ឲ្យបានផ្សាយចេញទៅប្រទេសក្រៅផង ។

ឯសាលាបាលីជាន់ខ្ពស់ ដែលមាននៅក្នុងប្រទេសកម្ពុជាយើងនេះ អាចញុំាងពួកបព្វជិតជានិស្សិតអ្នករៀនសូត្របានចេះដឹងវិជ្ជា គ្រាន់តែអាចបំពេញកិច្ចការព្រះពុទ្ធសាសនាសម្រាប់ប្រទេសរបស់ខ្លួនយ៉ាងមធ្យមប៉ុណ្ណោះ មិនអាចនឹងផ្សាយព្រះពុទ្ធសាសនាពីប្រទេសរបស់ខ្លួនទៅនានាប្រទេសបានឡើយ ហើយពុំអាចនឹងទៅបំពេញមុខការប្រាស្រ័យខាងផ្លូវសាសនាជាមួយនឹងពុទ្ធសាសនិកជនក្នុងនានាប្រទេសបានផង ដោយហេតុពុំបានចេះភាសាបរទេសល្មមគ្រប់គ្រាន់ ។ ការខ្វះខាតចំណេះវិជ្ជាខាងភាសាបរទេសនេះ នាំឲ្យពួកបព្វជិតជានិស្សិតខ្វះសេចក្ដីអង់អាចខ្វះគំនិតដែលត្រូវគិតធ្វើឲ្យព្រះពុទ្ធសាសនាបានចំរើនប្លែកពីធម្មតា ហើយថែមទាំងខ្វះយោបល់ដ៏ថ្លៃថ្លាផងទៀត ។

អាស្រ័យហេតុដូចខាងលើនេះហើយ ទើបព្រះករុណាជាអម្ចាស់ជីវិតលើត្បូងដែលទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ទ្រង់សព្វព្រះរាជហឫទ័យ នឹងពង្រីកការសិក្សាខាងព្រះពុទ្ធសាសនាឲ្យបានធំទូលាយឡើង ឲ្យសមតាមកាលៈទេសៈនៃប្រទេសឯករាជ្យ ទើបទ្រង់មានព្រះរាជបញ្ជាមកក្រសួងធម្មការ ឲ្យពិនិត្យមើលហើយចាត់ការរៀបចំពង្រីកការសិក្សា ឲ្យបានចំរើនឡើង ។

ក្រសួងធម្មការ បានទទួលព្រះបរមរាជឱង្ការហើយ ចាត់ការតាំងគណៈធម្មការមួយក្រុម នឹងអនុគណៈកម្មការ ១ ក្រុម ដើម្បីរៀបចំរបៀបបង្រៀនក្នុងសាលាបាលីជាន់ខ្ពស់ ព្រមទាំងរៀបចំបង្កើតឲ្យមានការសិក្សាថ្នាក់ខ្ពស់ឡើងទៀតគឺបង្កើតឲ្យមាន មហាវិទ្យាល័យខាងព្រះពុទ្ធសាសនាហៅថា "ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ", ការរៀបចំនោះកំពុងតែប្រព្រឹត្តទៅជិតដល់ទីបំផុតហើយ ។

ក្នុងការពង្រីកការសិក្សានេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានប្រារព្ធដល់ទីកន្លែងសម្រាប់សង់គ្រឹះស្ថានជាកន្លែងសិក្សា ហើយទ្រង់បានសម្រេចឲ្យយកទីដីនេះ គឺដីដែលមានគោលស៊ីម៉ង់ត៍ព័ទ្ធជុំវិញនេះហើយ ទុកជាកន្លែងសង់គ្រឹះស្ថានសម្រាប់សិក្សាវិជ្ជាខាងព្រះពុទ្ធសាសនា ។ ហើយទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ១ សែនរៀលសម្រាប់កសាងមហាវិទ្យាល័យពុទ្ធសាសនា ព្រមទាំង

ស្ដេចយាងមកជាព្រះរាជាធិបតីភាពបញ្ចុះបឋមសិលា នាថ្ងៃសុភមង្គលនេះទុកជា ព្រះមហាករុណាទិគុណយ៉ាងប្រសើរបំផុតតទៅ ។

ការរៀបចំបង្កើតឲ្យមានមហាវិទ្យាល័យ ខាងពុទ្ធសាសនានេះ នាំឲ្យពួកពុទ្ធបរិសទ្យខ្លួនទៅមានសេចក្ដីត្រេកអរគ្រប់គ្នា ក្នុងពួកពុទ្ធបរិសទ្យទាំងនោះ មានគហបតី១នាក់ឈ្មោះ ប៉េ-យ៉ាន ជាអ្នកជំនួញ កើតសេចក្ដីត្រេកអរជ្រះថ្លាមុនគេ បានតាំងចិត្តជាកុសលយ៉ាងមាំថា នឹងកសាងគ្រឹះស្ថានមួយខ្នង បណ្ដោយ២៤ម៉ែត្រ ទទឹង១២ម៉ែត្រ ធ្វើជាកន្លែងសិក្សាព្រះពុទ្ធសាសនា ។ ក្នុងមហាវិទ្យាល័យថ្មីនេះ ប្រមាណ ៣ខែកន្លងមកហើយ លោកគហបតី ប៉េ-យ៉ាន បានចាត់ចែងទិញគ្រឿងសម្ភារៈផ្សេង ៗ មានឥដ្ឋស៊ីម៉ង់ត៍ទឹនដែកជាដើម យកមកដាក់ទុកនេះ បំរុងនឹងកសាងឲ្យឆាប់បានសម្រេច ហើយនឹងឧទ្ទិសគ្រឹះស្ថាននេះ ទុកជាសម្បត្តិរបស់ព្រះពុទ្ធសាសនា សម្រាប់ជាទីសិក្សាបំណេះវិជ្ជារបស់កុលបុត្រ ក្នុងព្រះពុទ្ធសាសនា ព្រមទាំងប្រគល់គ្រឹះស្ថាននេះ ជូនចំពោះព្រះរាជរដ្ឋាភិបាលទុកជាសម្បត្តិរបស់រដ្ឋ ដែលមានព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាប្រមុខតរៀងទៅ ។

លោកគហបតី ប៉េ-យ៉ាន ដែលចំណាយធនធានរបស់ខ្លួនសាងគ្រឹះស្ថានដូច្នេះ ដោយសេចក្ដីពេញចិត្តណាស់ ព្រោះយល់ឃើញថាជាការមានប្រយោជន៍ដល់ព្រះពុទ្ធសាសនាផង ជាការជួយដល់ប្រទេសដែលកំពុងតែមានការខ្វះខាតផង ដើម្បីនឹងបំពេញព្រះរាជបំណងរបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងឲ្យបានសម្រេចដោយប្រពៃផង ។

សូមទ្រង់ព្រះមេត្តាប្រោស ក្នុងអវសានកថានេះ ទូលព្រះបង្គំជាខ្ញុំសូមសំបួងសង្រួងគុណព្រះរតនត្រ័យ សូមអភិបាលរក្សាព្រះករុណាថ្លៃវិសេស សូមទ្រង់ប្រកបដោយជោគជ័យសិរីសួស្ដីគ្រប់ទិវារាត្រីកុំបីឃ្លាត, សូមអភិបាលរក្សាសម្ដេច, ទ្រង់, ឯកឧត្តម និងអស់លោកអ្នកទាំងឡាយ ឲ្យបានសុខចំរើនអស់កាលជាអង្វែងរៀងទៅ ។

លុះចប់សុន្ទរកថានេះ ព្រះភូមិន្ទទ្រង់ស្ដេចយាងទៅប្រតិស្ឋានស៊ីម៉ង់ លាយដោយដីខ្សាច់ដាក់លើពានប្រាក់ដែលលោក គហបតី ប៉េ-យ៉ាន បុត្រីពីររូបកូនប្រសារប្រុសពីរនាក់ និងក្រុមញាតិទ្រគោរពថ្វាយហើយ ដែលព្រះមហាក្សត្រិយ៍ទ្រង់យកព្រះហស្ថចាប់ស្លាបព្រាចូកវត្ថុនេះ ដាក់ទៅក្នុងរណ្ដៅ ស្រេចហើយទើបរំកិលបឋមសិលាបញ្ចុះ



ព្រះករុណាទ្រង់ប្រតិស្ឋានស៊ីម៉ង់

ប្រធានក្រុមប្រឹក្សាជាតិ, លោកហ៊ុតគុម្មិស្ស្រ នឹងអគ្គទូត បានប្រស់ទឹកបឋមសិលានេះបន្តមកទៀត ជាកិច្ចឧត្តមបង្កបង្កើតមហាវិទ្យាល័យនេះឡើង ។

យើងសូមបញ្ជាក់ទៀតថា គ្រឹស្ថានដែលកំពុងមានការចាប់ផ្តើមធ្វើឡើងនេះដាក់នាមថា " ក្រុងមហាវិទ្យាល័យព្រះសីហនុរាជ " មានបណ្តោយ ៤៤ម៉ែត្រ ទទឹង ១២ ម៉ែត្រ ចំនួន ៣ ជាន់ ។ ទីដីនេះតាំងនៅត្រង់ស្រង់វិថីទុកញ៉ាឈុន និងតវ៉ៃ ស៊ីសុវត្ថិ ត្រង់កន្លែងផ្សារសួនចាស់ ហើយដែលនៅខាងជើងសាលាបាលីជាន់ខ្ពស់ពីលើ ព្រមតាំងទ្រង់ប្រោសព្រះរាជទានសុគន្ធវារីលើបឋមសិលានេះផង ។

ក្នុងពេល ដែលព្រះមហាវីរក្សត្រិយ៍កំពុងប្រតិស្ឋានបឋមសិលាជានិមិត្តរូបនេះ ព្រះសង្ឃបានស្វាធ្យាយជយន្តោ ប្រសិទ្ធិជោគជ័យជាមួយនឹងព្រះរាជករណីយកិច្ចផង; បន្ទាប់ពីព្រះមហាវីរក្សត្រិយ៍មកសម្តេចសង្ឃនាយកតាំងពីរគណៈ នឹងសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាសមាជិករដ្ឋាភិបាល ព្រះរាជប្រតិភូផ្ទាល់ព្រះអង្គ



នេះជាសិលាសម្រាប់បញ្ចុះ



គហបតី ប៉េ-យ៉ាន និងបុត្ររបស់លោក

មាននាទីដីបណ្ដោយ ៨០ម៉ែត្រ នឹងទទឹងជាង ៦០ ម៉ែត្រជាព្រះរាជអំណោយ នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលព្រះអង្គបានព្រះរាជទាន ឲ្យកសាងមហាវិទ្យាល័យនេះឡើង ដើម្បីពង្រីកកិច្ចសិក្សាខាងព្រះពុទ្ធសាសនា ឲ្យធំទៅតែខ្ពង់ខ្ពស់ សំរាប់សិក្ខាកាមកុលបុត្រ ។

នៅនាទីដីនេះ យើងឃើញគំនរឥដ្ឋក្រៀបក្រា ដែលជាស្នាដៃនៃលោកគហបតី ប៉េ-យ៉ាន និងគ្រួសារ បានមានសទ្ធាជ្រះថ្លាបរិច្ចាគធនធានព្រមទាំងបានចាត់ការ, ម៉ឺងម៉ាត់ដោយខ្លួនឯងបំរុងនឹងកសាងឲ្យបានឆាប់ៗ ជាប្រយោជន៍យ៉ាងបន្ទាន់ក្នុងពេលដែលប្រទេសជាតិកំពុងត្រូវការ ។

សមាគមមិត្តសាលាបាលី មានសេចក្ដីសង្ឃឹមថា តទៅអនាគតគង់មានពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លាដូចលោកគហបតី ប៉េ-យ៉ាន នេះច្រើនទៀត ដែលយល់ប្រយោជន៍ ជាតិ សាសនា មហាក្សត្រិយ៍ អាចជួយស្រោចស្រង់មាតុភូមិឲ្យបានចំរើនរុងរឿងក្នុងពេលដែលទើបនឹងបានឯករាជ្យថ្មីៗនេះ ។

ពិធីបុណ្យបញ្ចុះបឋមសិលានេះ បានបញ្ចប់នៅម៉ោង ៩,៣០ នាទី ក្រោយពេលដែលព្រះមហាវីរក្សត្រិយ៍ ស្ដេចយាងត្រឡប់ទៅកាន់ព្រះបរមរាជនិវេសវិញ ។

ចាប-ពិន

# សន្និសិទព្រះតេជព្រះគុណពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ (ត)

វត្តតាយាទ ឥឡូវនេះគេទុកជាហោសៀវភៅផង ជាកន្លែងសម្រាប់ប្រជុំកិច្ចការផ្សេងៗផង ទីង ជាសម្បត្តិរបស់វត្តកង់ក្រុងតូក្យូ ។ អ្នកប្រតិភូដំណាងប្រទេសនានាទាំងនោះ ជាអ្នកកាន់ព្រះពុទ្ធសាសនាខ្លះ; គ្រិស្តសាសនាខ្លះ, ឥស្លាមិកសាសនាខ្លះ, ហិណ្ឌូសាសនាខ្លះ, ជាបព្វជិតខ្លះ, គ្រហស្ថខ្លះ ទាំងក្នុងប្រទេសជប៉ុនក៏លាយឡំគ្នាដូច្នោះដែរ; ប្រតិភូទាំងនោះឥតមានការប្រកាន់អ្វីឡើយ ព្រោះសុទ្ធតែជាសន្តិជនអ្នកប្រាថ្នាសេចក្ដីសុខស្ងប់ដូចគ្នា ។

សន្តិជនទាំងនោះជាដំណាងប្រទេសដូចតទៅ៖

១- អាមេរិក, ២- អង់គ្លេស, ៣- កាណាដា ៤- អូស្ត្រាលី, ៥- ម៉ិកស៊ិកូ (អាមេរិក) ៦- កម្ពុជា, ៧- លង្កា, ៨- វៀតណាម, ៩- កូរ៉េ, ១០- ថៃ (សិស្សជំនួស) ១១- ភូមា (សិស្សជំនួស) ១២- ឥណ្ឌៀ, ១៣- បាគិស្ថាន, ១៤- ហាវ៉ៃ, ១៥- ជប៉ុន ។

បើកប្រជុំម៉ោង៩ព្រឹក លោកស៊ិរូមា សាសនាគ្រិស្ត (Shiruma) ថ្លែងសុន្ទរកថាទទួលអំណរចំពោះគណៈប្រតិភូ បន្ទាប់មកលោក តគុដូ កុរុម (Takudokuruma) រើសប្រធាន ១០ រូបដូចបានផ្គង់ទុកមកពីថ្ងៃមុន, រួចលោកអតីតនាយករដ្ឋមន្ត្រី តៈកៈយៈម៉ា (Takayama) មកថ្លែងសេចក្ដី



ប្រធានថ្លែងសេចក្ដី

រួចទើបអ្នកដំណាងប្រទេសថ្លែងសុន្ទរកថាបញ្ចេញយោបល់វៀនវួន; ការថ្លែងនៃគណៈប្រតិភូគ្រប់ប្រទេសក្នុងពេលនោះ រួមសេចក្ដីទៅមានដំណើរស្របទៅតាមផ្លូវតែមួយ គឺ ការស្វែងរកសន្តិភាព និង ការបំបាត់សង្គ្រាមក្នុងលោក; ថ្ងៃដំបូងនេះពួកអ្នកប្រជុំមានចំនួនជា២០០នាក់ រួមទាំងជប៉ុនផង; ចំណែកបព្វជិតខាងថេរវាទ គឺប្រទេសកម្ពុជា២, លង្កា៥, ឥណ្ឌៀ១ រួមជា៨រូប; ម៉ោង១១បានលើកការប្រជុំ ។ ម៉ោង១រសៀលចូលប្រជុំទៀត ម៉ោង៦ឈប់១លើក ប្រជុំពីប្រទេសកូរេតទៅទៀត ។ ការប្រជុំតពីម៉ោង៦ ទៅយើងមិនបានទៅប្រជុំទេ យើងត្រូវទៅហោតិលមិកសាកៃកាន់ ដោយលោកដុកទ័រ **Makato Nagai** និមន្តទៅជួបជុំជាមួយនឹងពុទ្ធសាសនិកជនជាតិជប៉ុនខាង (**Hongauji**) នឹងជាតិឥណ្ឌៀ ជាការប្រស្រ័យសាំដែងមិត្តភាពរវាងអ្នកកាន់ព្រះពុទ្ធសាសនាដូចគ្នា ក្នុងទីនោះមានការជប់លៀងអាហារភោជន ចំណែកយើងទទួលមិនបាន ត្រូវបត់តែខាងគ្រហស្ថ; (លោកដុកទ័រ

Nagai មិនបាននៅលោក Tomomatsu មកជំនួស) គង់ពេលនោះយើងមិនបាននៅយូរឡើយ យើងគ្រាន់តែសំដែងសេចក្ដីអរគុណ លោកធមិវរៈប្រែជាអង់-គ្លេសហើយបែកព្រះតម្រុយតូចៗ ទើបនាំគ្នាត្រឡប់មកជាន់ទូតវិញនៅម៉ោង៨កន្លះយប់ ; គ្នាឯទៀតនៅអាស្រ័យកោដនាហោតិលនោះតទៅ ។

ក្រោយមកយើងបានដំណឹងថា ដែលមិនបានទៅប្រជុំ នៅថ្ងៃសៀលនោះ គេមានសេចក្ដីស្ដាយយើងជាអនេក ដោយពេលនោះ គេមានរៀបជប់លៀងអាហារយ៉ាងវិសេសមួយ ដែលមានបន្ទមួយមុខរបនាដោយផ្លែពៅ ការដែលគេនឹកស្ដាយនោះ ព្រោះផ្លែពៅជនជាតិជប៉ុនគេហៅថាកាំប៉ូជៈ (Kam poja) ហើយគេចង់បង្ហាញយើងឲ្យឃើញហេតុដែលប្រទេសជប៉ុន នឹងកម្ពុជរដ្ឋធ្លាប់មានការទាក់ទងគ្នាជាច្រើនសតវត្សមកហើយ គេបានដឹងថា ការដែលមានពាក្យថា កម្ពុជៈនឹងជប៉ុនធ្លាប់មានការទាក់ទងគ្នានេះ ឬជាមិត្រមេត្រីនឹងគ្នានោះ មានអ្នកកាសែតខ្លះបានជជែកឡើងថាប្រទេសជប៉ុនពុំធ្លាប់ជាមិត្រនឹងប្រទេសអាស៊ីប៉ែកខាងអគ្នេយ៍ទេ ទើបមានអ្នកនិពន្ធ១ នាក់ជ-ជែកឡើងថាការដែលពោលនេះ ខុសស្រឡះប្រទេសកម្ពុជាធ្លាប់មានការទាក់ទងដោយមេត្រីភាព នឹងគ្នាជាយូរណាស់មកហើយ ។ ឧទាហរណ៍ដូចជាផ្លែកាំប៉ូជៈនេះ យើងបានយកផ្លែនេះមកប្រទេសយើង ដោយហេតុមិនស្គាល់ឈ្មោះ ក៏ហៅថាកាំប៉ូជៈ មួយវិញទៀតដូចជាសរសៃខិបញ្ញុក-ម៉ស្ទូ-តុយទារ ជនជាតិជប៉ុនហៅថាខគ្គិកាលពីពេលនោះ ជនជាតិជប៉ុនបានឃើញសរសៃខិបញ្ញុក-ម៉ស្ទូ-ម៉ីនៅក្រុងខគ្គិមានជ័យ ហើយក៏សួរអ្នកខគ្គិថានេះជាអ្វី អ្នកខគ្គិស្មានថាសួរនាមទីក្រុង ក៏ឆ្លើយប្រាប់ថាខគ្គិ សព្វថ្ងៃនៅប្រ-ទេសជប៉ុនគេហៅខិបញ្ញុក-ម៉ស្ទូ-ម៉ី-តុយទារថាខគ្គិ ទាំងអស់ជនជាតិជប៉ុនក៏ជឿបានថា ពិតជាជប៉ុននឹងកម្ពុជាធ្លាប់ជាមិត្រនឹងគ្នា ជាយូរណាស់មកហើយមែន;មានភាសាខ្លះដូចគ្នាដោយសុទ្ធសាធដូចជាពាក្យថាខ្សៀជប៉ុន ហៅថា ខ្សៀ ឬកាំបិតតាំងគោ ជប៉ុនហៅថា តាំងតូ ។ល។ ដូចនេះគេយល់បានថាជប៉ុនពិតជាធ្លាប់មានមិត្តភាពនឹងកម្ពុជៈជា យូរណាស់មកហើយ ។

ថ្ងៃ ទី ២ មេសា-៥៤ ម៉ោង ៩ព្រឹក បើកការប្រជុំនៅទីកំងអាកាសកាងដែល; ពេលនោះលោក ដុកទ័រ Kalidas Nag ធ្វើប្រធាន បានឲ្យឱ-កាសដល់ប្រតិភូផ្សេងៗថ្លែងយោបល់ ខាងគណៈប្រ-តិភូខ្មែរក៏ចូលថ្លែងយោបល់ដែរ តែការថ្លែងគង់ពេលនោះពុំទាន់ពិស្ដារទេ គ្រាន់តែថ្លែងជាខ្មែរបន្តិចបន្តួច ទើបប្រគល់ឲ្យលោកគ្រូធមិវរៈប្រែជាអង់គ្លេស, ដល់ម៉ោង ១១ លើកប្រជុំ ។ ចំណែកយើងបានទៅផ្ទះលោក Tomomatsu ទទួលបង្អែម ដោយលោក-

នោះបានទិមន្តទុកតាំងពីថ្ងៃមុន; ការប្រជុំនឹងចាប់បើក នៅម៉ោង៩រសៀលតទៅទៀត មណ្ឌលនោះធ្វើនៅមន្ទីរ មហោស្រពសាធារណៈ ហ៊ុប៊ីយា ពួកគណៈប្រតិភូ ប្រទេសនានា គេឲ្យអង្គុយលើវេទិកាជាមួយនឹង ប្រធាន នឹងក្រុមចាត់ការ ឯមហាជនជប៉ុនអង្គុយ ផ្ទាក់ក្រោមបែរមុខមករកវេទិកា. រួមប្រមាណដោយ តិចជា ៣-៤ពាន់នាក់ លោកប្រធានបានបើកសម័យ ប្រជុំ ហើយគណៈប្រតិភូក៏បានថ្លែងសេចក្ដីរៀងខ្លួន តាមពាក្យហៅរបស់លោកប្រធាន; លើកនេះគណៈ



គណៈប្រតិភូប្រទេសកម្ពុជាបានលើកយកព្រះពុទ្ធរូបប្រកនាគ ជូនទៅលោកប្រធាន

ប្រតិភូប្រទេសកម្ពុជាបានលើកយកព្រះពុទ្ធរូបប្រក នាគមួយអង្គ ជារបស់ពុទ្ធិកសមាគមប្រទេសកម្ពុជា ជូនទៅលោកប្រធាន នឹងលោកភូយី កណ្ដាល ប្រជុំធំ ពួកមហាជនបានទះដៃឲ្យពរសព្ទសាធុការ ទទួលអំណរ មានលោក១រូបឈ្មោះសាតូ បានថ្លែង ប្រាប់មហាជនថា ព្រះពុទ្ធរូបដែលគណៈប្រតិភូប្រ-ទេសកម្ពុជាប្រគល់មកនេះជារបស់ពុទ្ធិកសមាគមកម្ពុជា ជូនមកទុកជាសម្បត្តិព្រះពុទ្ធសាសនា នៅប្រទេស ជប៉ុន, មហាជនក៏ទះដៃព្រមគ្នាម្ដងទៀត ។

តមកលោកគ្រូធម្មវិរៈ ថ្លែងជាភាសាអង់គ្លេស ថា ព្រះពុទ្ធរូបដែលយើងនាំមកដំកល់នាប្រទេស ជប៉ុននេះ សូមឲ្យអស់លោកទាំងឡាយជ្រាបបាន ថាជាសុភនិមិត្តមួយយ៉ាងប្រសើរ ព្រោះព្រះពុទ្ធនេះ ហើយ ដែលជាតួអង្គនៃអ្នកស្វែងរកសុខសន្តិភាព បានមុនគេ; ឥឡូវព្រះអង្គបរិនិព្វានហើយសល់ នៅតែព្រះរូប យើងបាននាំយករូបព្រះពុទ្ធដែលជា ម្ចាស់នៃសុខសន្តិភាព មកដំកល់ទុកក្នុងទីនេះប្រា-កដដូចជាយើង បាននាំមកនូវសុខសន្តិភាពមកប្រគល់ ឲ្យដល់អ្នកពល់គ្នា សូមឲ្យអ្នកទាំងឡាយខំប្រឹងពក-យាម ឈោងចាប់យកសុខសន្តិភាព ដូចជាព្រះពុទ្ធ ដែលមានរូបជាដំណាងនេះ; កុំបីខានឡើយ ពួកមហា ជនទះដៃទទួលអំណរព្រមគ្នាដោយក្រៃលែង ។



គណៈប្រតិភូប្រទេសកម្ពុជាធ្វើជាប្រធាន

ចប់កិច្ចប្រជុំហើយ គេលេងរបាំ កំប្រៀងរួច

បញ្ចាំងកុន ពីរឿងទម្លាក់គ្រាប់បែក បរមាណូ នៅហិរោស៊ីមា ....ចប់ម៉ោង ៥,៣០ ។

ថ្ងៃទី ៣ មេសា-៥៤ ម៉ោង ៩ ព្រឹកបើកប្រជុំនៅទីតាំងការសភា, មន្ត្រីនៃប្រទេសកម្ពុជាត្រូវគេបានតាំងឲ្យធ្វើជាប្រធាននៃការប្រជុំ ; ខ្ញុំបានថ្លែងសេចក្ដីបើកសម័យប្រជុំជាភាសាខ្មែរថា: ខ្ញុំមានអំណរជាទីបំផុតចំពោះមហាសន្និបាតដែលបានតាំងខ្ញុំ ឲ្យធ្វើជាប្រធាន ដំណែងនេះមិនមែនជាកិត្តិយសដល់ខ្ញុំប៉ុណ្ណោះឡើយ គឺដល់ប្រទេសកម្ពុជា ដែលទើបនឹងបានទទួលឯករាជ្យថ្មីៗផងទៀត រូបលោកធម្មិវរៈប្រែជាភាសាអង់គ្លេស នឹងថ្លែងបន្តចំនួន២៥មីនុតចប់ ។ (សេចក្ដីថ្លែងនោះពិស្ដារណាស់ មិនអាចយកមកចុះទីនេះឲ្យសព្វគ្រប់ទេ កាលចប់ហើយពួកអ្នកស្ដាប់យកចិត្តទុកដាក់គ្រប់គ្នា លោក(Dr Kalidas Nag) បានប្រាប់ខ្ញុំថា គាសាប្រាពិនថា សេចក្ដីថ្លែងព្រឹកមិញនេះល្អណាស់នាំឲ្យមានកិត្តិយសយ៉ាងប្រសើរ ដល់ខ្លួនលោក ព្រោះជាកិត្តិយសយ៉ាងថ្លៃថ្លារបស់ប្រទេសកម្ពុជា នាំឲ្យគេស្គាល់បានថា ប្រទេសកម្ពុជា ជាប្រទេសឯករាជ្យ ហើយកាន់ព្រះពុទ្ធសាសនាយ៉ាងពេញលេញ; ម្យ៉ាងទៀត សេចក្ដីថ្លែងនេះទុកជាគំនូសមួយ ដែលបានចូលទៅក្នុងជាប់មិនលប់ក្នុងចិត្តអ្នកស្ដាប់គ្រប់គ្នា-

លំដាប់តមក អ្នកដំណាងប្រទេសផ្សេងៗ ក៏ថ្លែងសេចក្ដីជាលំដាប់តមក ; មានការជជែកគ្នាពីបញ្ហាផ្សេងៗ ជាភាសាអង់គ្លេស រឿងនេះជាភារៈលើលោកគ្រូធម្មិវរៈ លោកអាចនាំមកថ្លែងបាន ខ្លួនខ្ញុំស្ដាប់ពុំបានសព្វគ្រប់ទេ -

(មានត)

---

# អត្ថបទដែលយើងបានទទួល

គណៈកម្មការទស្សនាវដ្ដីមិត្តសាលាបាលី បានទទួលអត្ថបទពិសេសមួយស្ដីពីទ្រឹស្ដីលើសាសនា,ការសិក្សា និងវប្បធម៌ នៃជម្ពូទ្វីប អំពីព្រះមហា គួច-គីឡេង (ប៊ិតប្បញ្ញោ) មហាឧត្តមវិជ្ជា សាលាបាលីជាន់ខ្ពស់ដែលសព្វថ្ងៃនៅបំពេញវិជ្ជាខាងព្រះពុទ្ធសាសនានាអសោកវិហារ ក្រុងញូដែល្ហី រាជធានីប្រទេស-ឥណ្ឌៀផ្ញើមក ។

យើងមានសេចក្ដីសោមនស្សជាទីបំផុត, បានចុះអត្ថបទនេះទាំងស្រុង ឥតកែប្រែទេ ដូចតទៅនេះ ៖

## ដំណឹងពីជម្ពូទ្វីប

### ១– ទ្រឹស្ដីលើសាសនា

ជម្ពូទ្វីបជាប្រទេសមួយដែលតាំងនៅក្នុងភាគខាងលិចនៃអាស៊ីទ្វីប, ទិសពាយ័ព្យនៃប្រទេសកម្ពុជា មានឈ្មោះល្បីល្បាញជាច្រើនសតវត្សរ៍ក្នុងពង្សាវតារខាងព្រះពុទ្ធសាសនា ។ ប្រទេសទាំងឡាយអ្នកកាន់ព្រះពុទ្ធសាសនា ដូចជា លង្កា, ភូមា, សៀម, ខ្មែរ, លាវ, យួន, ចិន ជប៉ុនជាដើម បានស្គាល់នូវពាក្យ

ថា "ជម្ពូទ្វីប" យ៉ាងជាក់ច្បាស់ ដែលសព្វថ្ងៃគេច្រើនតែហៅថា "ឥណ្ឌៀ" តាមភាសាអង់គ្លេស និងតាមភាសារៀងៗខ្លួន មានពាក្យថា ហិណ្ឌុស្ថាន, សិន្ធុស្ថាន, ភារតៈជាដើម ។ ពុទ្ធសាសនិកជនទាំងឡាយអាចចេះចាំនូវពង្សាវតាររបស់ជម្ពូទ្វីបក្នុងបុរាណសម័យដោយច្បាស់លាស់ គឺដឹងចំពោះទីណាដែលមានព្រះពុទ្ធសាសនាផ្សាយទៅដល់ ។ ក្នុងពុទ្ធសម័យជម្ពូទ្វីបធ្លាប់ជាមហាអំណាច ដែលមានអារ្យធម៌, វប្បធម៌ និងសីលធម៌ខ្ពង់ខ្ពស់ ។ ការកាន់វណ្ណៈក៏មិនមានក្នុងពុទ្ធកាលនោះដែរ ។ ភាសាបាលីធ្លាក់ទៅជារដ្ឋភាសា គឺភាសាសម្រាប់ដែនតាមពង្សាវតារឥណ្ឌៀ បន្ទាប់ពីពុទ្ធកាលមកអស់កាលជាយូរឆ្នាំ ជម្ពូទ្វីបក៏នៅតែរុងរឿងរហូតដល់រជ្ជកាលនៃព្រះបាទធម្មាសោក ។ ព្រះបាទធម្មាសោកជាមហារាជមួយអង្គដែលគេស្គាល់ថាបានលើកស្ទួយព្រះពុទ្ធសាសនា ឲ្យជាសាសនាសម្រាប់ដែនរបស់ជម្ពូទ្វីប ។ តាមពង្សាវតារឥណ្ឌៀមាននិយាយថា "ព្រះបាទធម្មាសោកមិនមែនគ្រាន់តែទ្រង់បានធ្វើការល្អ ៗ ច្រើនចំពោះតែព្រះពុទ្ធសាសនាក្នុងជម្ពូទ្វីបទេ ថែមទាំងទ្រង់បានបញ្ជូនសាសនទូតទៅប្រទេសផ្សេងៗ ជាច្រើនទៀត មានបញ្ជូនទៅអឺរ៉ុប, អាហ្វ្រិក, ពែរ្ស៊ិកប្រទេស (Iran) យោនកលោក(Greek) ភោដប្រទេស (Tibet) ចិនប្រទេស (China) ជាដើមរហូតដល់ទ្រង់បានបញ្ជូនព្រះមហាមហិន្ទត្ថេរនិងព្រះនាងសង្ឃមិត្តាថេរី ដែលជាព្រះរាជបុត្រាបុត្រីរបស់ព្រះអង្គជាទីបំផុត ឲ្យនិមន្តទៅលង្កាទ្វីប នាំជាប់ជាមួយព្រះអង្គលោកនូវព្រះពោធិព្រឹក្សមួយមែកផង ដើម្បីប្រតិស្ឋាននៅទីនោះ" ។

បន្ទាប់ពីព្រះបាទធម្មាសោកទីវង្គតទៅ វង្សត្រកូលនេះ គឺមោរិយខត្តិយត្រកូល ក៏ដុនដាបជាលំដាប់ ដោយហេតុថា "មិនជាធម្មិករាជ" ស្តេចក្នុងប្រទេសដទៃជាអ្នកកាន់សាសនាឥស្លាមស្វែងរកទោស បានចូលមកច្បាំងយករាជសម្បត្តិ បានប្រតិស្ឋានសាសនាឥស្លាម ដោយការប្រើអាការកំហែងមានទំលាក់អំណាចនិងការសម្លាប់ជាដើម ។ អស់កាលជាច្រើនសតវត្សរ៍ បន្ទាប់ពីនោះមក ទើបសាសនាព្រាហ្មណ៍ផ្សាយចូលមកកន្លែងដើមវិញជាលំដាប់ អស់រយៈកាលច្រើនឆ្នាំទាល់តែសាសនានេះបានទទួលអំណាចខ្លាំងឡើងវិញ ក៏បណ្តាលទៅជាជំលោះដ៏ធំរវាងសាសនានិងសាសនាទាំងពីរនេះ ។ បណ្តាលមកពីហេតុនៃសាសនា, ប្រជាជនបានទទួលទុក្ខលំបាកជាច្រើនក្នុងពេលនោះ ដោយហេតុថា ប្រជាជនមិនមានសាមគ្គីធម៌ ព្រោះតែកាន់សាសនាផ្សេងៗពីគ្នា ។ ដោយអាស្រ័យជំលោះនៃសាសនាទាំងពីរនេះកាន់តែខ្លាំងឡើង ៗ ទាល់តែបណ្តាលឲ្យកើតសាសនាមួយទៀត ហៅថា "សាសនាសិក្ខ" សព្វថ្ងៃតាំងនៅក្នុងជម្ពូទ្វីបត្រង់ព្រំប្រទល់ជាទីធ្វើកាត់នៃបាគិស្ថាននិងហិណ្ឌុស្ថាន ។ សាសនានេះ កើតឡើងដោយអ្នក

ប្រាជ្ញម្នាក់ "គុរុនានក:" ជាអ្នកពូកែខាងការកាប់សម្លាប់ ។ គេបង្កើតឡើងដោយជួយការសង្គ្រោះពួកហិណ្ឌូ កុំឲ្យពួកឥស្លាមសម្លាប់បាន ប៉ុន្តែជាប់ទៅជាសាសនាមួយរហូតដល់សព្វថ្ងៃនេះ, សាសនានេះកើតឡើងរវាង៤សតវត្សរ៍ហើយ មានពាសពេញក្នុងជម្ពូទ្វីប ។ អ្នកកាន់សាសនានេះត្រូវទុកពុកមាត់, ពុកចង្កា, សក់ឲ្យនៅតាមប្រក្រតី មិនត្រូវកោរសោះឡើយ ហើយជួតក្បាលធំសំពោង ។ គេអាចប្រទះឃើញតាមកាលតាមសម័យខ្លះនៅប្រទេសកម្ពុជាយើង ដូចជាពួកកាប៉ប់ដើរទិញគោជាដើម ។ សាសនានេះមិនល្បីល្បាញចេញមកខាងក្រៅពីជម្ពូទ្វីបទេ ។ ប្រជាជាតិខ្មែរយើងមិនដែលដឹងថាជាសាសនាអ្វីដែរ សូម្បីតែឈ្មោះក៏មិនដែលឮផង ។

បន្ទាប់ពីនោះមក ពួកកាន់សាសនាយេស៊ូដែលជាតិពរទុយគេស (**Portuguese**) នាំចូលមកទៀត (សាសនាយេស៊ូ ឥណ្ឌូ ហៅថាឥសាគុំ, ព្រះយេស៊ូ ហៅថា ឥស៊ុ) នៅបានប្រហែលជា៤០ឆ្នាំ ។ ក្នុងឆ្នាំ ១៧៨៧ ជាតិអង់គ្លេសដោយមានកងទ័ព[illegible]ប់មកផង ចូលមកដេញពរទុយគេសចេញ, នាំគ្នាធ្វើជាតុលាការ ដើម្បីកុំឲ្យមានការតាស់តែងខ្វែងគំនិតរវាងសាសនានិងសាសនា ។ ប៉ុន្តែមិនយូរប៉ុន្មាន អង់គ្លេសញុំាងអ្នកកាន់សាសនាទាំងសង្ខាងឲ្យខូចការ ទាល់តែធ្លាក់អំណាចមកលើដៃអង់គ្លេសពង្រីកអាណាចក្រ យកធ្វើជាអាណានិគមបាន នៅរហូតដល់ថ្ងៃ ១៥ សីហា ១៩៤៧ ទើបចេញទៅវិញ ។ ក្នុងរយៈកាល ១៩០ ឆ្នាំ ដែលអង់គ្លេសមកកាន់អំណាចនៅប្រទេសឥណ្ឌា បានញុះញង់អ្នកសាសនាទាំងពីរ គឺសាសនាព្រាហ្មណ៍និងឥស្លាមឲ្យបែកបាក់ សាមគ្គីរវាងគ្នានិងគ្នា រហូតដល់មានការបែកស្រុកទេសទៅជាពីរជាដើម គឺហិណ្ឌូស្ថាននិងប៉ាគិស្ថានសព្វថ្ងៃ ។ ដោយអាស្រ័យហេតុដូចពោលមកនេះ បានជាព្រះពុទ្ធសាសនាក្នុងជម្ពូទ្វីបរៀវរោយចុះជាលំដាប់ ស្ទើរតែគេពុទ្ធសាសនិកគ្មានក្នុងសម័យនោះ ។ សម័យនេះត្រឡប់ជាមានរើបា បន្តិចឡើងវិញហើយ ។

កាលក្នុង ព.ស. ២៤៣៦ គ.ស. ១៨៩២ មានឧបាសកម្នាក់ឈ្មោះអនាគារិកធម្មបាល ជាកូនអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ចេញពីលង្កាទ្វីប មកកាន់ជម្ពូទ្វីប បានប្រតិស្ឋានព្រះពុទ្ធសាសនាទុកក្នុងទីនេះមានការតាំងមហាពោធិសមាគម និងផ្សាយទស្សនាវដ្ដី ដោយភាសាផ្សេងៗ ដាក់ឈ្មោះថា "ទស្សនាវដ្ដីមហាពោធិសមាគម" ជាដើម រហូតមកដល់សព្វថ្ងៃនេះ ។



នេះគឺអនាគារិកធម្មបាលឧបាសក ជាតិលង្កា ដែលបានប្រតិស្ឋានព្រះពុទ្ធសាសនានៅជម្ពូទ្វីប ក្នុង ព.ស. ២៤៣៦ ។

## ២- ការសិក្សា

ក្នុងជម្ពូទ្វីបមានការសិក្សាបរិបូណ៌ណាស់តាំងសម័យអតីត តាំងសម័យបច្ចុប្បន្ន ។ ពង្សាវតារឥណ្ឌៀមាននិយាយថា "ក្នុងពុទ្ធសម័យនិងអសោកសម័យ មានប្រជាជនចេះដឹងច្រើនជាងសម័យឯទៀត" ។ ព្រោះហេតុនោះបានជាសព្វថ្ងៃគេឃើញសិលាចារិក របស់ព្រះបាទធម្មាសោកនៅពាសពេញក្នុងជម្ពូទ្វីបដែលសរសេរភាសាបាលី ជាអក្សរព្រាហ្មណ៍ ។ មានច្រើនជាងគេ គឺនៅក្នុងពារាណសី(១) ឬកាសី (ហៅបេណារេសសព្វថ្ងៃ);រាជគ្រឹះ, បាតលីបុត្ត,មគធ: (ហៅពិហារសព្វថ្ងៃ); កាលិង្គ

(១) ក្រុងចាស់ ពារាណសីនឹងកាសីនេះ គឺតែមួយហ្នឹងឯង នៅជាប់ព្រំប្រទល់ចម្ងាយ ៣ គីឡូម៉ែត្រពីគ្នា ។ កាលពីដើមបានជាឈ្មោះនេះល្បីល្បាញណាស់ ដូចជានគរពីរធំៗ ព្រោះស្ដេចជាន់នោះមានអំណាចខ្លាំង សូម្បីសោយរាជ្យក្នុងនគរតូចៗដូចឃុំតូចមួយជាន់នេះ ក៏ដូចជាធំណាស់ទៅហើយ ។ សព្វថ្ងៃគេហៅជាឃុំសារនាថ ឃុំកាសី ស្រុកបេណារេស (ពារាណសី) ជាទីក្រុងខេត្តរបស់ឧត្តរប្បទេស ។

(ហៅចារិស្សាសត្វថៃ); វគ្គៈ; គោសម្ពី (ហៅបេគ្គាល់សត្វថៃ) ។ នៅក្នុងទីដទៃទៀតក៏មានខ្លះដែរតែមិនសូវច្រើន ។ ដូចជានៅឃុំសារនាថស្រុកពារាណសី មានសសរលញ្ញមូលធំមួយកំពស់ ៦ ម៉ែត្រ មានសត្វសីហៈ ៤ នៅចំពីលើកំពូលដាក់ទុកនៅក្នុងវត្តក្បែរកន្លែងដែលព្រះអង្គទ្រង់សំដែងធម្មចក្កប្បវត្តន-សូត្រនឹងអនត្តលក្ខណសូត្រ សរសេរជាសាបាលីអក្សរព្រាហ្មណ៍ថា:

សមគ្គោ ហោតុ សង្ឃោ ន ភិន្ទា ភវេ
យេ ភេទេ វិសុទ្ធិ តេន អលជ្ជី ភវេយ្យុំ ។
យថា យំ និស្សាយ អសមគ្គា អលជ្ជិកានំ នានា



ហេតុតោ ការណំ ឧប្បន្នំ, សោ និគ្គណ្ហាតព្វោ,
អនុសាសេតព្វោ អថវា ។

នេះគឺ សសរស្តម្ភរបស់ព្រះបាទធម្មាសោក នៅស្រុកពារាណសី ឃុំសារនាថ ត្រង់កន្លែងដែលព្រះអង្គទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រ ខាងក្រោយសាលានិយមបាសក ។ សសរស្តម្ភនេះគេសាងឡើងក្នុងសតវត្សរ៍ទី ៣ នៃ ព.ស. ។

សសរស្តម្ភនេះ ពួកឥស្លាមបានវាយបំបាក់បំបែកខូចខាតអស់ហើយខាងក្រោម នៅតែខាងលើនេះឯង វាយមិនបាក់ ។ សត្វថៃគេយកទៅដាក់ទុកក្នុងពិពិធភណ្ឌក្រុងពារាណសី (**Benares Museum**) រដ្ឋាភិបាលឥណ្ឌៀបានយកគម្រូសសរស្តម្ភនេះ ធ្វើជារូបភាពត្រាសម្រាប់ប្រើជារបស់ប្រជាជាតិសត្វថៃ ហើយយកគម្រូកងដែលបិតនៅចំកណ្តាល ធ្វើជាមណ្ឌលទង់ជាតិ ។ គេឃើញឥណ្ឌៀចម្លងយកបែបផែន



របស់ព្រះបាទធម្មាសោកមកប្រើជាច្រើនសតវត្សនេះ ។

ការសិក្សាតាមកាលៈទេសៈជាសម័យបច្ចុប្បន្ន គឺជនជាតិឥណ្ឌាបានទទួលអារ្យធម៌ និងវប្បធម៌ខ្ពស់ជាងគេដែរនៅក្នុងកាលសម័យនេះ ។ តាំងពីជំនាន់អង់គ្លេសចូលមកពង្រីកអាណាចក្រ បាននាំយកអារ្យធម៌ ,វប្បធម៌ និងសីលធម៌ មកផ្សាយផង ដើម្បីទុកឲ្យជនជាតិឥណ្ឌា ប៉ុន្តែឥណ្ឌាមិនបានផ្ដិតចម្លងយកទាំងអស់ទេ យកតែរបស់ណាដែលខានពុំបាន ដូចជាការសិក្សា, តិកនិក មានការបង្កើតយានជំនិះ តាមផ្លូវអាកាស ផ្លូវទឹក, ផ្លូវគោក, រោងអគ្គិសនី, ឬក៏ពាណិជ្ជកម្ម, ឧស្សាហកម្ម ជាដើមប៉ុណ្ណោះឯង ។ ឯអារ្យធម៌មានការស៊ីបុក, ស្លៀកពាក់ជាដើម និងសីលធម៌ ឥណ្ឌាមិនបានផ្ដិតយកផងទេ ។ សីលធម៌ ឬកមារយាទរបស់ឥណ្ឌា អន់ណាស់តែអារ្យធម៌បានចំរើនគួរសម ព្រោះបេះផ្សាយឲ្យចូលទៅក្នុងខ្លះបាន ។ គេឃើញនៅពាសពេញទីក្រុងដេលហ្លី (Delhi) មានស្រីអង់គ្លេស អាមេរិក ស្លៀកសំពត់ជាបែបឥណ្ឌា ។

ការសិក្សារបស់កុមារកុមារីជាតិឥណ្ឌា ត្រូវតែប្រញាប់ប្រញាល់ពីក្មេងៗណាស់ បើពុំដូច្នោះទេ នឹងនាំឲ្យយឺតយូរពេល ព្រោះថាមុននឹងចូលទៅរៀននៅសាលាណាមួយ គេឲ្យរៀនភាសារបស់ខ្លួនសុទ្ធ ៥ឆ្នាំសិន ។ បន្ទាប់ពីនេះចូលឆ្នាំទី ៦ ទើបចាប់ផ្ដើមរៀនភាសាអង់គ្លេស, រៀនអង់គ្លេស៦ឆ្នាំទៀតរួមទាំងអស់ជា១១ឆ្នាំ តាំងពីឆ្នាំទី ១មក ទើបមានសំណាងប្រឡងយកវិញ្ញាបនបត្រ (Certificat) បាន លុះបានប្រឡងជាប់ហើយ ទើបចូលទៅរៀននៅមហាវិទ្យាល័យផ្សេងៗ (Collège) ដែលរួមចូលក្នុងអគ្គមហាវិទ្យាល័យ (University) ។ មកដល់ថ្នាក់នេះ គេបែងចែកអស់ហើយ អ្នកណាចង់រៀនខាងណា ស្រេចតែចិត្តស្ម័គ្រ គេនឹងបញ្ជូនទៅតាមសេចក្ដីប៉ងសុំរបស់បេក្ខជន, ព្រោះថានៅប្រទេសឥណ្ឌាមានមហាវិទ្យាល័យគ្រប់បែបទាំងអស់ គឺមហាវិទ្យាល័យសម្រាប់អក្សរសាស្ត្រ, ច្បាប់, នយោបាយ, ឱសថ (ថ្នាំកែរោគ), សុខភាព, តិកនិក, យុទ្ធសាស្ត្រ, ទស្សនវិជ្ជា, តក្កវិជ្ជា, ឧស្សាហកម្ម, ពាណិជ្ជកម្ម, កសិកម្ម ។ ក្នុងឈ្មោះមួយៗមានសាលា ២ ឬ ៣ ជាដរាប សម្រាប់សិស្សដើម្បីកុំឲ្យខ្វះក្នុងមួយឆ្នាំៗ ។ សាលាប្រុស-ស្រីមានដោយឡែកៗពីគ្នា សម្រាប់ស្រីគេហៅថា នារីមហាវិទ្យាល័យ(Womeñs Collège) ក្នុងខេត្តនីមួយៗមានមហាវិទ្យាល័យគ្រប់បែបដូចខាងលើនេះ, រួមទាំងអស់ហៅថា អគ្គមហាវិទ្យាល័យ (University) ។ ដូច្នេះនៅរាល់ខេត្តមានអគ្គមហាវិទ្យាល័យ មួយប្រចាំជានិច្ច ។ ខ្លះមាន ២, ខ្លះមាន ៣, ខ្លះមាន ៤, មិនមានដល់៥ ឡើយ តាមខេត្តធំ-តូច, ដូចខេត្តឧត្តរប្រទេស, មជ្ឈិមប្រទេស, ខេត្តពិហារ, ខេត្តបេង្គាល់ជាដើម សុទ្ធតែមាន ៣-៤

ព្រោះជាថៃត្រជំ ៗ ណាស់ធំជាងប្រទេសយើងទៅទៀត ៗ សិស្សដែលប្រឡងជាប់ត្រូវបានចូលរៀនមិនអាចនឹងរកទីលំនៅអាស្រ័យបានដោយងាយទេ ព្រោះនៅប្រទេសឥណ្ឌា មិនមានការឲ្យប្រាក់ខែ, បាយស៊ីដល់សិស្សដូចនៅស្រុកយើងទេ វៀរលែងតែនិស្សិតពិសេស ដែលមកពីប្រទេសផ្សេង ៗ ដែលសុំតាមផ្លូវរាជការមកទើបរាជការឥណ្ឌាគេសុខចិត្តទទួលឲ្យនៅរៀនសូត្រ សុខចិត្តចិញ្ចឹម ដើម្បីជាកិត្តិយសរបស់ប្រទេសគេ ។

ចាប់តាំងពីក្រោយការប្រឡងជាប់វិញ្ញាបនបត្រមកការសិក្សារបស់សិស្សទាំងឡាយ ត្រូវរៀន ៤ ឆ្នាំទៀតទើបប្រឡងយកសញ្ញាប័ត្របាន ហៅថា "**B.A.**" (**Bachelor of Arts**) ប្រែថា "ព្រហ្មចារីបុគ្គលជាអ្នកអក្សរសាស្ត្រ;" បន្ទាប់ពីនេះ ពីរឆ្នាំទៅទៀត ប្រឡងយកសញ្ញាប័ត្រមួយទៀត ហៅថា "**M.A.**" (**Master of Asts**) ប្រែថា "បុគ្គលជាម្ចាស់នៃអក្សរសាស្ត្រ" ។ បន្ទាប់ពីនេះ ក៏រៀនតាមលំដាប់ថ្នាក់ទៅទៀត ដរាបដល់ថ្នាក់អគ្គមហាបណ្ឌិត (**Doctor**) ជាទីបំផុត ។ នៅប្រទេសឥណ្ឌាការរៀនសូត្រមិនមានកំណត់អាយុទេ ទោះបីក្មេងចាស់មានប្រពន្ធហើយក៏អាចប្រឡងបានតាមចិត្តឲ្យតែមានសមត្ថភាព ។ វិជ្ជាស្ថានពិសេស (**Spécial Institution**) មានល្មមគ្រប់គ្រាន់ សម្រាប់ជួយសង្គ្រោះដល់អ្នកដែលប្រឡងធ្លាក់, ព្រោះហេតុនោះ អ្នកដែលមានអាយុច្រើន ៗ ហើយប្រឡងមិនជាប់ងាយចេញពីសាលាទៅធ្វើការរកការចិញ្ចឹមជីវិតក៏មាន នៅរៀនសូត្រតទៅទៀតក៏មាន, ទៅរៀបចំវិវាហ៍(១)មង្គលក៏មាន, ឬ ឈប់តែម្ដងទៅក៏មាន, តែអាចចូលមកប្រឡងក្នុងពេលដែលរាជការបើកឲ្យប្រឡងនោះបាន បើចង់ ។

## ការធ្វើដំណើរទៅរៀននៃសិស្សទាំងឡាយ

សិស្សទាំងឡាយ សុទ្ធតែនៅក្នុងទីផ្សេង ៗ គ្នា

---

(១) ការរៀបចំវិវាហមង្គលនៅឥណ្ឌូទ្វីប ផ្សេងណាស់ គឺច្បាប់រដ្ឋធម្មសាស្ត្រអនុញ្ញាតឲ្យរៀបមង្គលការតែម្ដងគត់ក្នុងមួយជីវិត ។ ទោះបីប្ដីឬប្រពន្ធស្លាប់ក៏ដោយក៏ពោងតែនៅជាពោះម៉ាយឬ មេម៉ាយទៅ ។ បើចង់រៀបមង្គលការនឹងអ្នកដទៃម្ដងទៀត អាចរៀបបាន ប៉ុន្តែអ្នកនោះនាងនោះឯងឈ្មោះថា "លក់ត្រកូល, បង្ខូចជាតិ" ។ អ្នកមានត្រកូល,មានមុខមាត់ទាំងឡាយតែងតែប្រកបដោយសេចក្ដីក្រែងច្បាប់នេះច្រើន ។ ម្នាក់ ៗ មិនអាចយកប្រពន្ធពីរ ឬ ប្ដីពីរបានឡើយ ទោះបីអ្នកនោះជាមនុស្សថ្នាក់ណាក៏ដោយ ដូចលោកបណ្ឌិត នេហរូ នាយករដ្ឋមន្ត្រីឥណ្ឌូទ្វីបឬលោកស្រី វិជយលក្ស្មី បណ្ឌិត ប្រធានាធិបតីអង្គការសហប្រជាជាតិ ជាបងប្អូនបង្កើតនឹងគ្នាជានរាហណ៍, ប្រពន្ធប្ដីទទួលមរណភាពបោលទៅជាយូរហើយ តាំងពីមិនទាន់បានធ្វើជានាយករដ្ឋមន្ត្រី, ប្រធានាធិបតី គឺកាលកំពុងបើកនៅក្នុងមជ្ឈិមវ័យម្ល៉េះ ក៏នៅតែ ជាពោះម៉ាយ, មេម៉ាយរហូតដោយមិនហ៊ានប្រព្រឹត្តកន្លងប្រពៃណីរបស់ប្រទេស ។ ព្រោះហេតុក្លឹងហើយបានជាឥណ្ឌារ៉ាម្លួនណាស់ក្នុងប្រពៃណីនេះ ។ ប្ដីប្រពន្ធមិនមានអំណាចត្រូវលែងគ្នាបានឡើយ ។ ច្បាប់រដ្ឋធម្មសាស្ត្រនេះជាទំនៀមទំលាប់ជាប់ជាប្រពៃណីច្រើនសតវត្សរ៍មកហើយ ។ ការរៀបមង្គលការគឺប្រុសស្ដីស្រី តែស្រីត្រូវជូនជំនូនបងប៉ុណ្ណងដែនឹងរៀបពិធីការ ។ ប្រុសពីអាយុ ២៨ ឡើង ទើបអនុញ្ញាតឲ្យមានប្រពន្ធ, ស្រីពីអាយុ ២០ឡើងទៅ ។

ឆ្ងាយៗពីសាលារៀនរបស់ខ្លួន ប្រហែលជា ៤ គីឡូម៉ែត្រក៏មាន ៥-៦-៧ ដល់ ១០ គីឡូម៉ែត្រក៏មាន មិនអាចដើរទៅរៀនបានដោយស្រួល ៗ បើចង់នៅជិតសាលារៀនក៏បាន ប៉ុន្តែត្រូវជួលផ្ទះឈ្នួល បង់ថ្លៃតាមខែ ៗ ធម្មតាសិស្សទាំងឡាយ តែងប្រកបដោយសេចក្តីទីទាល់ក្រ មិនអាចនឹងធ្វើដូច្នោះទៅបាន ព្រោះម្តាយឪពុកមិនជាអ្នកមានធនធានគ្រប់គ្រាន់ ៗ អាស្រ័យហេតុនេះ រដ្ឋាភិបាលរៀបចំការឲ្យបានចំរើនរួសរាន់ ដល់ប្រជាជននិងសិស្ស គឺដាក់ឲ្យឡានឈ្នួលរត់គ្រប់ផ្លូវទាំងអស់ ១៤ នាទី ចេញមួយ ៗ ចាប់តាំងពីជ្រុងខាងក្រៅទីក្រុង បរកាត់ក្រុង សំដៅទៅកាន់ស្ថានីយ៍អាយស្ម័យយាន ហួសអគ្គមហាវិទ្យាល័យ ត្រឡប់ពីស្ថានីយ៍អាយស្ម័យយានមកវិញ ចេញទៅខាងក្រៅក្រុង ៗ ថ្លៃឈ្នួលទាំងនេះមានពណ៌តែមួយ, បែបតែមួយ សុទ្ធតែជារបស់រដ្ឋាភិបាល មើលទៅជាទីមនោរម្យដល់ភ្នែក គួរឲ្យសរសើរ ហេតុតែរដ្ឋាភិបាលគេចេះរៀបចំការបានល្អ ៗ ហេតុនេះ សិស្ស, អ្នកធ្វើការនិងប្រជាជនទាំងឡាយ អាចទៅរៀនទៅធ្វើការបានយ៉ាងស្រួល ៗ គេយកថ្លៃឈ្នួលពីសិស្សសាលាប្រុសស្រីតិចជាងប្រជាជននិងអ្នកធ្វើការណាស់ ប្រហែលជា ១/៣ ៗ សិស្សទាំងឡាយអាចចូលទៅបង់ប្រាក់ប្រចាំខែ ហើយរាជការចេញបណ្ណសម្រាប់ជិះឲ្យ ៗ

គេឃើញសិស្សទាំងប្រុសទាំងស្រីនៅទីកន្លែងរថយន្តចេញពីផ្ទះទៅរៀនដោយរហ័សរហួនដូចជាសំដែងឲ្យឃើញថា "ឲ្យទាន់ពេល" ទាំងទៅទាំងមក ៗ នៅសាលារៀន សិស្សទាំងឡាយអាចធ្វើបាននូវករណីគ្រប់យ៉ាង ដូចអ្នកធ្វើការ ៗ

អ្នកជម្ពូទីបប្រឹងប្រែងធ្វើការណាស់ ទាំងប្រុសទាំងស្រី ទាំងនាម៉ឺនទាំងរាស្ត្រ មិនថាអ្នកមានអ្នកក្រ ៗ សូម្បីប្រជារាស្ត្រប្រឹងប្រែងធ្វើការច្រើនដល់ម្ល៉ោះ ក៏រដ្ឋាភិបាលខំប្រឹងប្រែងធ្វើឲ្យបានច្រើនជាងប្រជារាស្ត្រទៅទៀត ព្រោះអ្នកធ្វើការជាអ្នកចេះដឹងច្រើនជាងប្រជាជន, គេធ្វើការត្រឹមត្រូវល្អណាស់ យោងមុខប្រជារាស្ត្រជានិច្ច, ប្រកបដោយសុចរិតយុត្តិធម៌ សមគួរដល់ភាពជាអ្នកចេះដឹង និងជាអ្នកដឹកនាំប្រជាជន, ព្រោះហេតុនេះហើយ បានជាប្រទេសឥណ្ឌាបានទទួលសេចក្តីចំរើនទាន់សម័យ ដែលសព្វថ្ងៃមហាប្រទេសទាំងឡាយក្នុងលោកអាចទាយទុកបានថា " តទៅអនាគត ជម្ពូទីប នឹងក្លាយទៅជាការប្រទេសមួយក្នុងលោកដ៏រុងរឿង" ជាប្រាកដ ៗ ឯប្រទេសកម្ពុជាយើង បើតាមពិនិត្យមើល ប្រៀបធៀបទៅនឹងប្រទេសគេ ឃើញថាអ្នកធ្វើការធ្វើការតិចជាងពលរដ្ឋ ប្រជារាស្ត្រនាំមុខអ្នកធ្វើការជានិច្ច នៅប្រទេសសៀមក៏ដូចគ្នា ៗ ហេតុនេះចាប់តាំងពីថ្ងៃខែឆ្នាំនេះទៅ ក្នុងបណ្តាប្រទេសទាំងឡាយនោះ ប្រទេសកម្ពុជាមួយដែរដែលបានគេ

តាមខុតដូចគ្នា និងមានសេចក្ដីសង្ឃឹមថា "ជម្ពូទ្វីបនិងកម្ពុជាគ្រាន់តែស្គាល់គ្នាច្បាស់លាស់" ព្រមទាំងជឿថា "អារ្យធម៌របស់កម្ពុជានិងជម្ពូទ្វីប ក្រភពជា និងបានផ្ដិតចម្លងបែកគ្នាទៅវិញទៅមក ថែមទាំងជាមិត្តភាពដ៏ជិតស្និទ្ធដូចសម័យទសវត្ត" ជាប្រាកដពុំខានឡើយ ។ សមនឹងសុន្ទរកថារបស់ ឯ.ឧ. សឺន-សាន អគ្គតំណាងប្រទេសកម្ពុជាយើង បានថ្លែងពីថ្ងៃសៅរ៍ ៧ សីហា ១៩៥៤ នៅក្រុងដែលីជាទីប្រជុំសន្និសីទរវាងប្រទេស ថា "កម្ពុជរដ្ឋឋិតនៅក្នុងកិរិយាណា នាំទៅកាន់សេចក្ដីចំរុងចំរើនមានស្នេហ៍រកឯករាជ្យនិងសន្តិសុខជាដើមនៃព្រះករុណាជាម្ចាស់ជីវិតជាមួយនឹងប្រជាជនរបស់ព្រះអង្គបាននាំខុតក្នុងចិត្តជារៀងៗដោយមិនមានសង្ស័យថាអារ្យធម៌ (Civilisation) របស់ជាតិខ្មែរចេញមកអំពីជម្ពូទ្វីប ។ អស់កាលជាច្រើនសតវត្សរ៍ហើយកម្ពុជានិងជម្ពូទ្វីបមិនដែលបានស្គាល់គ្នាសោះ, ថ្ងៃនេះ ជាឱកាសមួយដ៏ល្អដែលបើកឲ្យខ្ញុំសំដែងនូវមិត្តភាពដល់ជម្ពូទ្វីបជាបឋមជាលើកទី ១ និងអាចចងភ្ជាប់នូវអារ្យធម៌តាមគោលដើមវិញបាន មានការរាប់អានព្រះពុទ្ធសាសនាជាដើម, ហេតុនេះសូមជម្ពូទ្វីបនិងប្រទេសទាំងឡាយ ដែលនៅក្នុងអាស៊ីទ្វីបជឿច្បាស់ថា កម្ពុជាបានទទួលនូវឯករាជ្យនិងសន្តិសុខបរិបូណ៌ហើយ(១) ។

(១)ប្រែចាកកាសែតអង់គ្លេស ដកយកតែត្រង់អារ្យធម៌ក្នុងកាសែតឈ្មោះ "ជម្ពូទ្វីបសម័យ" ចេញពីក្រុងដែលី ថ្ងៃអាទិត្យទី ៨ សីហា ១៩៥៤ ។

## ៣-ផ្នែកវប្បធម៌

ឥណ្ឌាមានវប្បធម៌ទូលំទូលាយណាស់ ។ វប្បធម៌ឥណ្ឌា មានច្រើនពេកលំបាកនឹងសរសេរអន្ទងយកមកចារទុកក្នុងទីនេះឲ្យសព្វគ្រប់ ព្រោះថាកាលដែលអង់គ្លេសមកចាប់យកឥណ្ឌាធ្វើជាអាណានិគមបានបំបែកឲ្យមានសាខាច្រើនទៅតាមខេត្តតាមស្រុក ដូច្នេះភាសាខ្លះមានវប្បធម៌គ្រប់គ្រាន់ ភាសាខ្លះមានមិនគ្រប់គ្រាន់ ប៉ុន្តែបើទុកជាច្រើនដល់ម្ល៉េះក៏គង់ឥណ្ឌាចេះរក្សាវប្បធម៌របស់ខ្លួនឲ្យគង់វង់នៅបានដរាបដល់សព្វថ្ងៃនេះ ។ អង់គ្លេសបានញុំាងឥណ្ឌាឲ្យរៀនភាសាខ្លួន ដើម្បីកុំឲ្យវប្បធម៌គង់វង់នៅបានរហូតដល់សព្វថ្ងៃ ភាសាដែលបែកចេញទៅតាមស្រុកខេត្តជាភាសាធំៗបានបៀមជាប់នូវវប្បធម៌មាន ១៥ គឺៈ ១-ហិណ្ឌី, ២-ឧរឌូ, ៣-ម៉ារ៉ាធី, ៤-បេង្គាលី, ៥-ទមិលី, ៦-ប៉ាន់យ៉ាប, ៧-គុជ្ជរាតី, ៨-អស្សាមី, ៩-តេលគុ, ១០-កាណារី, ១១-កាណាឌ, ១២គុរមុខី, ១៣-ឧរិស្ស, ១៤-កស្មីរ៍, ១៥-ជម្មូ ។ ភាសាទាំងនេះសុទ្ធតែមានលំនាំស្រដៀងៗគ្នានឹងអក្សរទេវនាគរី ហើយសុទ្ធតែខ្ចីភាសាសំស្ក្រឹតមកប្រើ លើកលែងតែអក្សរឧរឌូលេខ ២ចេញ ដែលមានលំនាំស្រដៀងនឹងអក្សរអារ៉ាប់ទៅវិញ បើហិណ្ឌីលេខ១និងម៉ារ៉ាធីលេខ៣គឺសរសេរជាអក្សរទេវនាគរីសុទ្ធសាធ ហើយខ្ចីភាសាសំស្ក្រឹតមកប្រើច្រើនជាងគេផង ។ គេអាចនិយាយបានថា បើភាសាទាំងនេះប្រើជាផ្លូវការធំៗ ដូចជាប្រើនៅក្នុង

ក្រសួងនឹងក្នុងការិយាល័យផ្សេងៗជាផ្លូវនយោបាយក្តី ជាការបរបាតាមផ្លូវសារពត៌មានមានកាសែតជាដើមក្តី ប្រើជាផ្លូវតក្កវិជ្ជា ( Science ) មានទស្សនវិជ្ជា, មានសិកសាស្ត្រ, មនោវិញ្ញាណសាស្ត្រជាដើមក្តី ប្រើជាផ្លូវតិកនិកឬសាជីវកម្ម មានឧស្សាហកម្ម, ពាណិជ្ជកម្មឬកសិកម្មជាដើមក្តី គេឃើញភាសាសំស្រ្កឹតមកប្រើ ៦០/១០០ ឬ ៦៥/១០០ ។

សូមដកស្រង់យកវប្បធម៌សំខាន់ៗខ្លះមកទុកជាឧទាហរណ៍ដូចខាងក្រោមនេះ៖

| អង់គ្លេស | ខ្មែរ | ឥណ្ឌា (ហិណ្ឌី) |
|---|---|---|
| Mathematics | គណិតសាស្ត្រ | គណិតសាស្ត្រ |
| Arithmetic | ក្បួនពន្ធ ឬ លេខាគណិត | អង្កគណិត |
| Geometry | រេខាគណិត | រេខាគណិត |
| Algebra | ពីជគណិត | ពីជគណិត |
| Physic | ( ? ) | សរីរិកសាស្ត្រ |
| Physiology | ( ? ) | សរីរវិញ្ញាណសាស្ត្រ |
| Phylosophy | ទស្សនវិជ្ជា | ទស្សនវិជ្ជា |
| Psychology | ( ? ) | មានសិកសាស្ត្រ |
| Phonetic | សូរសាស្ត្រ | សូរសាស្ត្រ |
| Metaphysic | ( ? ) | អាធ្យាត្ម |
| Phychology | ( ? ) | មនោវិញ្ញាណសាស្ត្រ |
| Science | តក្កវិជ្ជា | តក្កវិជ្ជា |
| Astrology | តារាសាស្ត្រ | នក្ខត្តសាស្ត្រ |
| Politic | នយោបាយ | រាជនីតិ |
| Ethic | នីតិសាស្ត្រ | នីតិសាស្ត្រ |
| Citezen | ពលរដ្ឋ | នាគរិក |
| Economic | សេដ្ឋកិច្ច | អថ៌សាស្ត្រ |
| Independence | ឯករាជ្យ | ស្វតន្ត្រតា |
| Photo | រូបថត | ចិត្រ |
| Concentration | សមាធិ | សមាធិ |
| Commerce | ពាណិជ្ជកម្ម | វាណិជ្យ |
| Library | បណ្ណាគារ | បុស្តកាល័យ |
| Pharmacy | ឱសថាល័យ | ឱសថាល័យ |
| Restaurant | ភោជនីយដ្ឋាន | ភោជនាល័យ |
| Bureau | ការិយាល័យ | ការិយាល័យ |
| Minister | រដ្ឋមន្ត្រី | មន្ត្រី |
| Prime Minister | នាយករដ្ឋមន្ត្រី | ប្រធានមន្ត្រី |
| Président | ប្រធានាធិបតី | រដ្ឋបតិ |
| Republic | សាធារណរដ្ឋ | ( ? ) |
| United State of America | សហរដ្ឋអាមេរិក | អាមេរិកសំយុក្តរដ្ឋ<br>អមេរិកាយានទ្វីបសំយុក្តរដ្ឋ |

ឯពាក្យដទៃទៀតក៏មានច្រើនដែរ ជាពាក្យសាធារណ៍ទូទៅ ជាវប្បធម៌ជាន់ចាស់ ស៊ាំមាត់តាំងឥណ្ឌៀតាំងខ្មែរទៅហើយដូចជាខ្មែរជាមនុស្សដែរ ;

គឺថាមនុស្សដែរ, រូបក៏រូប, កាយក៏កាយ, ចិត្តក៏ចិត្ត, សរីរៈក៏សរីរៈ, អាត្មាក៏អាត្មា, ប្រាណក៏ប្រាណ, ភាសាក៏ភាសា, ប្រទេសក៏ប្រទេស, គ្រាមក៏គ្រាម, ជនបទក៏ជនបទ, ទ្វីបក៏ទ្វីប, ភូមិក៏ភូមិ; ឯសាលារៀនថា បាឋសាលា, ព្រះចន្ទក៏ចន្ទ, ព្រះអាទិត្យក៏អាទិត្យ ព្រះសូរ្យក៏សូរ្យ, មេឃក៏មេឃ, ទ្វារក៏ទ្វារ ប៉ុណ្ណេះ ជាដើម ចំណែកពាក្យខ្មែរ ថា ទឹកឥណ្ឌៀថា ជល ឬ បាន ផ្កាយថាតារា, ផ្ទះថាឃរៈ, សត្វពាហនៈ ថា បសុ, សៀវភៅមើល ថា បុស្តក, សត្វក្ងោក ថា មោរៈ, ស្ទឹង ឬ បឹង ថា នទី, ម៉ាស៊ីន ( Machine ) ថាយន្ត្រ, ផ្លូវ ថា មាគ៌ ជាដើម ។

សព្វថ្ងៃ ឥណ្ឌៀកំពុងប្រឹងប្រែងធ្វើការណាស់ដើម្បីនឹងភ្ជាប់ខ្សែវប្បធម៌ឱ្យចូលគ្នាតែមួយដូចដើមវិញ ។ ភាសាហិណ្ឌីជាភាសាសម្រាប់ផែនប្រើពេញប្រទេសឥណ្ឌៀទាំងមូល ។ នៅគ្រប់ទីតាំងអស់សុទ្ធតែត្រូវរៀនភាសាហិណ្ឌីជាដំបូង ហើយដល់ថ្នាក់ទុតិយដ្ឋាន (High school) ទើបត្រូវរៀនសំស្ក្រឹតនិងអង់គ្លេស តទៅ ។ ការរៀនអង់គ្លេសនៅប្រទេសឥណ្ឌៀពេលនេះ មិនសូវជាចំរើនណាស់ណាដែរទេ ព្រោះអាស្រ័យហេតុដូចពោលមកខាងលើ ។ នៅក្នុងអគ្គមហាវិទ្យាល័យនីមួយ ៗ មានសិស្សខ្លះមិនរៀនអង់គ្លេសទេ រៀនតែហិណ្ឌីនិងសំស្ក្រឹត ឬ បាលីប៉ុណ្ណោះ ។ ការរៀនបាលីមិនជាការចាំបាច់ប៉ុន្មានទេ នៅប្រទេសនេះ ព្រោះឥណ្ឌៀមិនមែនជាពុទ្ធសាសនិក ។ នៅតំបន់ខ្លះមានរៀនគួរសមព្រោះតែបង់ដីនៃព្រះពុទ្ធសាសនា ។ អ្នកនយោបាយទាំងឡាយ គេច្រើនតែរៀនភាសាសំស្ក្រឹតរៀនបេះដឹងសំខាន់ណាស់, នៅស្រុកនាលន្ទាជាស្រុកកំណើតព្រះសារីបុត្តត្ថេរ គង់គយាសីស ប្រទេស ដែលសព្វថ្ងៃហៅថា "ខេត្តពិហារ" ជាប់គ្នានឹងក្រុងមិថិលា មានការរៀនបាលីមាំមួនជាងទីដទៃ ( ការរៀនបាលីនៅប្រទេសយើងអស់រយៈកាលប៉ុន្មានឆ្នាំ គឺតាំងពីផ្តើមដំបូងរហូតដល់ប្រឡងចូលចេញពីសាលាបាលីជាន់ខ្ពស់ឃើញថា បានផលច្រើនណាស់ពីភាសាបាលីហើយ, ប៉ុន្តែមិនទាន់បានច្រើនសព្វគ្រប់នៅឡើយ ព្រោះការរៀនមិនបានចំណាប់និយាយប្រស្រ័យគ្នាដោយភាសាបាលី) ។ ភាសាហិណ្ឌីគេបានរៀបចំឱ្យរៀនដល់ថ្នាក់ អគ្គមហាបណ្ឌិត(Doctor)ហើយ ប៉ុន្តែមិនទាន់មានសិស្សណាបានទទួលសញ្ញាប័ត្រថ្នាក់នេះនៅឡើយទេ កំពុងតែរៀនយក ។

សេចក្តីដូចពោលមកខាងលើនេះទាំងប៉ុន្មានស ឲ្យឃើញថា តើឥណ្ឌៀបានចំរើនដល់ណាហើយ ? ព្រមទាំងបង្អួលបង្ហាញឱ្យឃើញថា សាសនាក្តី, គោលរបស់ជាតិក្តី, អារ្យធម៌ក្តី, វប្បធម៌ក្តី, សីលធម៌ក្តី, វិជ្ជាធម៌ក្តី, ការសិក្សាក្តី, ប្រពៃណីក្តី, អ្វីៗឯទៀតក្តី ដែលនឹងគង់វង្ស ឬ ចំរុងចំរើនទៅបាន អាស្រ័យដោយយើង

ធ្វើកើតបានឆាយ នូវអ្វីដែលគេឬយើងធ្វើមិនកើត ទើបហៅថាចម្រើន ព្រមទាំងអាស្រ័យដោយពលរដ្ឋ គ្រប់ជាន់ មានមនោសញ្ចេតនាល្អប្រកបដោយកត្តិ-ភាពបេះរក្សានូវមតិករបស់ជាតិខ្លួន ជាទីគោរពកោតក្រែងដល់ជាតិ, សាសនា និងព្រះមហាក្សត្រិយ៍ ដែលជាត្រៃសរណដ្ឋានរបស់យើង ។

ភិក្ខុ ឌួប.គីឡេង (បិតប្បញ្ញោ)

១៣-៨ ២៤៩៧/១៩៥៤

---

## ពិធីបុណ្យបញ្ចុះអដ្ឋិធាតុនិងសីមា



ព្រះសពនាម ស្រី-អ៊ុម

នៅវត្តកំពង់ធំ ឃុំកំពង់ធំ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ចំនួន ៤ ថ្ងៃ ចាប់តាំងពីថ្ងៃ ១៣ កើត ខែចេត្រ ដល់ថ្ងៃ ១ រោច ខែចេត្រ ព.ស.២៤៩៧ គ.ស.១៩៥៤ ទើបសម្រេចពិធី,

ព្រះពុទ្ធវង្ស កោវស៊ុម

រៀបរៀង តាមករណីយកិច្ច ព្រះសមុហ៍គណ អ៊ុក-ឡេង ជាអធិបតីនៃពិធីបុណ្យ និងថៅកែ គាន់-ហេង សូមឲ្យរៀបរៀង ។

បុណ្យនេះ មានគោលការណ៍ ២ យ៉ាង:

១-បញ្ចុះអដ្ឋិធាតុ ព្រះតេជព្រះគុណព្រះសព មេគណខេត្តកំពង់ធំ នាម ស្រី-អ៊ុម ក្នុងប្រាង្គណ៍ (ចេតិយធំ);

២-បញ្ចុះសីមា នៅទីវិហារដែលបានសាងថ្មី ពុំទាន់ហើយស្រេច ដើម្បីប្រគេនចំពោះព្រះសង្ឃធ្វើ សង្ឃកម្មទាំងពួង ក្នុងព្រះពុទ្ធសាសនាតរៀងទៅ ។

គោលបុណ្យទាំង ២ យ៉ាងនេះ ជាប្រធាននៃ កុសលកម្មរបស់អស់លោក-អ្នកទាំងគ្រហស្ថទាំង បព្វជិត ដែលជាពុទ្ធបរិស័ទក្នុងខេត្តកំពង់ធំ មាន ព្រះគ្រូវិរិយធម្មគុត្ត អនុគណ ប៉ុល-ង៉ិន, លោកគ្រូព្រះ សមុហ៍គណ អ៊ុក-ឡេង និងអាចារ្យសម្រាប់វត្តកំពង់ ធំ នាម សុខ-ប៊ុន ជាដើម ជាអ្នកប្រារព្ធចាត់ វិធានការដូចតទៅនេះ:

១-ពានូបករណ៍ មានដុំសិលាបុសសីមាជាដើម;

២-និមន្តព្រះសង្ឃចំនួន ២០០ អង្គ;

៣-ធ្វើរោង ៨ គ្រប់ទិសទាំង ៨;

៤-គ្រឿងតាំងផ្សេង ១ សម្រាប់តែងរោង ។

នៅថ្ងៃព្រហស្បតិ៍ ១៥ កើត ខែមីនា ចាប់ផ្ដើមបុណ្យឡើង ដោយមានស្មូត្រព្រះអាទិត្យរះត្រចៀង តាំងមកហើយក្ដៅផង នៅទីវត្តកំពង់ធំទាំងមូលគេបានឃើញរោងបុណ្យនោះស្អាតៗ មានបណ្ដាយ ១០ ម៉ែត្រខ្លះ, ១៥ម៉ែត្រខ្លះ, ទទឹង ៧ ម៉ែត្រខ្លះ, ៩ ម៉ែត្រខ្លះ ជារោងដែលគេបានធ្វើបំរុងទុកពីថ្ងៃមុនមក រួចហើយ ព័ទ្ធជុំវិញនៃវិហារ ។

លុះដល់ថ្ងៃបុណ្យប្រវេសនកាលគឺថ្ងៃចូលបុណ្យជាដំបូង គេបានសំគាល់ឃើញស្ថានភាពរបស់វត្តសព្វអន្លើ ដែលបានរៀបចំពិធីតាក់តែងបុណ្យគឺនៅក្នុងរោងបុណ្យនីមួយៗសុទ្ធតែតាក់តែងដោយគ្រឿងតាំង មានលំអដោយសូត្រក្រុងជាតិ ដើមឈើ ផ្កាឈើ ក្អមផ្កា រយោងរយាន នៅទីផ្ចាំងរោងពាសដោយផ្ទាំងសំពត់ស និងសំពត់មានពណ៌ល្អវិចិត្រដោយរូបភាពផ្សេងៗ មានរូបគំនូរជាតិបរទេស និងរូបបុរាណវត្ថុ ថ្លៃៗ ដែលជាស្នាដៃនៃការរចនារបស់បុរសខ្មែរសម័យដាច់ដើម មានទស្សនីយភាពល្អមើលយ៉ាងអស្ចារ្យ រូបទាំងនេះគេតាំងថ្វាយជាគ្រឿងសក្ការបូជាចំពោះព្រះបដិមាករ ដែលបានដាក់លើកនតាំង សម្រាប់ជារបស់លំអដល់ពួកពុទ្ធបរិស័ទអ្នកត្រូវការចូលមើល, នៅខាងមុខនិងខាងក្នុងរោងនីមួយៗ សុទ្ធតែមានពន្លឺភ្លើងអគ្គិសនីអំពូលតូចធំវែងខ្លីបញ្ចាំងរស្មីភ្លឺព្រោងព្រាតលាតជាប់គ្នាតាមមន្ទីររោងគួរឲ្យអ្នកផងចាប់ចិត្តជិតជាប់នឹងពន្លឺភ្លើងនោះ មនុស្សទាំងប្រុសស្រីមានមុខញញឹមប្រិមប្រិយ ដើរចុះឡើងប្រៀតប្រៀសដែកគ្នាចូលមើលគ្រឿងតាំងគ្រប់តែរោង ឥតមានថុញទ្រាន់លំបាកដោយហេតុអ្វីឡើយ, ខាងមុខរោងនីមួយៗ មានដោតទង់ជាតិ ទង់សាសនា សរសេរអក្សរនិងផ្ទាំងសំពត់ជាសុភាសិតភាសាបាលីនិងខេមរភាសា សម្រាប់បំភ្លឺពួកជនឲ្យចេះពិចារណាតាមយោបល់ពលគ្នា គឺពន្យល់ការឲ្យដឹងអំពីអក្សរសាស្ត្រជាតិជាកំពូលរបស់ជាតិ ទាំងការឲ្យចេះស្រឡាញ់ជាតិរបស់ខ្លួនជាដើម របស់ទាំងអស់នេះនាំឲ្យទាក់ចិត្តអាចទាញចក្ខុប្បសាទរបស់ជនប្រុសស្រីឲ្យគយគន់មើលមិនឈប់ឈរ នាំគ្នាត្រេកអរសាទរគ្រប់រូប ។

នៅទីកន្លែងវិហារដែលគេទើបកសាងថ្មីលើដីដែលគេលើកទួលខ្ពស់ មានរបៀបតាក់តែងដោយសូត្រក្រុងជាតិធ្វើជាស៊ុមអែបនែបតាមទ្វារវិហារ ជា



ពេលតាំងសួរភាព

សង្កាត់ៗ, ខាងក្នុងរៀបគ្រឿងសក្ការបូជាថ្វាយព្រះពុទ្ធរូបជាទឡ្ហិក, ទីយ៉ាងមុខវិហារ គេធ្វើបុស្បុកមួយយ៉ាងធំ មានក្បូរក្បាច់របនាំលេចដោយក៏ផ្កាតាមសម័យបុរាណកាល, របៀបខាងលើធ្វើជាកំពូលស្រួចដូចជាកំពូលចេតិយ, របៀបកណ្ដាលរៀបសណ្ឋានជាថ្នាក់ៗបាក់ជាក្បាច់រំលេចដោយក៏ស្រស់ ៗ រុំព័ទ្ធដោយទេសឯកស, របៀបខាងក្រោមមានស្ថានភាពជាកំពូងប្រកបដោយក្បាច់ របនាតាមរបៀបប្រពៃណីពីបុរាណ, បុស្បុកនេះ សម្រាប់ជាអាសនៈទទួលសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយផង ជាធម្មាសនៈសម្រាប់ធម្មកថិកសំដែង



រោងក្នុងពិធីបុណ្យ

ធម្មទេសនាផង គម្រំពីមុខវិហារចម្ងាយប្រហែលជា ៣០ ម៉ែត្រគេបានធ្វើស៊ុមទ្វារមួយយ៉ាងធំខ្ពស់ត្រដែត នៅចំមុខវិហារ របនាដោយរុក្ខជាតិស្រស់គ្រប់បែបក្បែរចិញ្ចើមមហាវិថីផ្លូវថ្នល់ធំ ដែលមកពីភ្នំពេញ សម្រាប់ជាសក្ការបូជាទទួលសម្ដេចព្រះមហាសុមេធាធិបតីនិងអស់លោកមន្ត្រីតូចធំ, នៅសងខាងនៃស៊ុមទ្វារចូលទៅកាន់ទីវត្តនោះមានទង់សាសនា និងទង់ជាតិចងលាតត្រដាងយ៉ាងវែងពីត្រឹមទីយ៉ាមុខវិហាររហូតដល់ទីស៊ុមទ្វារធំ, នៅជុំវិហារទាំង ៤ គេចងទង់ធំៗ វែងៗ នៅជាយក្រងមានព្រុយរហូតមកដល់គន្លុយវែងអន្ទាយត្រសាយត្រសុំ ដែលគេចងខ្សែបណ្ដោតបុះឡើងយ៉ាងខ្ពស់ត្រដឹមត្រដូចដូចពាងសត្វក្រពើ គេហៅថាទង់ក្រពើ គេធ្វើតាមទំនៀមទម្លាប់ប្រពៃណីពីបុរាណកាល ត្រង់ក្បាលទង់ធំៗទាំងនោះ ក្ងួរខ្នាលព្រាលប្រុះធុះស្រមោលពោលព្រាតៗចេញពីកញ្ចក់ប៉ុនៗ ភ្នែកមាន់ដែលគេដេរស្រះភ្ជាប់ជាប់ត្រង់ក្បាលទង់ផងខ្លួនទុកជាស្នៃនៃគេជាទុ-កាតរបស់ទង់ ។




ចេតិយធំ

នៅទិសឦសានជិតជ្រុងវិហារ ជាស្ថានភាពដែលគេរៀបចំប្លែកជាងទីឯទៀត ព្រោះជាទីប្រាង្គណ៍ (ចេតិយធំ) មានកំពស់ ១៩ ម៉ែត្រ ហាក់ដូចជាអណ្តែតទៅលើអាកាស, ចេតិយធំនេះហើយ! ដែលជាទីនិធានផ្នូនបញ្ចុះអដ្ឋិធាតុព្រះសព មេគណខេត្តកំពង់ធំ, នៅចំខាងមុខនៃចេតិយធំនោះ គេសង់រោងទីងបាំសម្រាប់ពុទ្ធាភិសេក មានរាង៤ជ្រុងស្មើ សណ្ឋានដំបូលដូចរាងសាជី ហើយមានឆត្រទ្រុងជម្រួតលើដំបូលនោះថែមទៀត នាផ្ទៃរោងទីងបាំគេគ្រាលបន្ទះក្តារបង្កើតអំពីផែនដី ទីខាងក្រៅគេធ្វើរបងតែតព័ទ្ធជុំវិញ ហើយចងទង់ជ័យនឹងទង់សា-សនាភាយតាមរបងតែនោះ ខាងក្នុងរោងគេរៀបចំដំកល់ព្រះពុទ្ធរូបលើកនតាំង សម្រាប់នមស្ការ ដ៏ប្រកបដោយគ្រឿងអលង្ការ ជាសក្ការបូជាយ៉ាងឧឡារិក ។



ចៅកែ តាន់-ហេង

ចំណែកតួចេតិយធំ មានចៅកែ តាន់-ហេង ជាអ្នកចាត់ចែងការជាប់មុខតែម្នាក់ឯង គឺគាត់តែងចេតិយរចនាជាក្បាច់រលេចដោយពន្លឺភ្លើងអគ្គិសនីព័ណ៌ខៀវ-លឿង-ក្រហមរុំស្រោបពេញព័ទ្ធតួចេតិយធំនោះចុះមកដល់ខឿនស្ថានក្រោមវៀងរហូតដល់ទីរោងពុទ្ធាភិសេកទីងបាំ, ពន្លឺភ្លើងអគ្គិសនីទាំងនេះដល់ពេលរាត្រីស្រាប់តែឃើញពន្លឺស្មើចេញមកពីស៊ុមទ្វារខ្លះ ដើមផ្កាឈើនោះខ្លះ ពីបង្កាន់ដៃ ៣ ថ្នាក់ដែលគេវិចិត្រលំអដោយកូនឈើនិងកូនផ្កា នៅទីចេតិយនោះខ្លះ គួរជាទីរីករាយសប្បាយចិត្តរាល់រាត្រីដល់បុរសស្ត្រីក្មេងចាស់ចូលទៅមើលដើរដាសពាសពេញទាំងយប់ទាំងថ្ងៃ ដោយមានចិត្តស្ម័គ្រក្តីអាលោះអាល័យចំពោះព្រះសព នាម ស្រី-អ៊ុម ដែលត្រូវជាគ្រូឧបជ្ឈាយាចារ្យរបស់ខ្លួន ។

ឯវិធានការនៃបុញ្ញកម្មដែលបានកំណត់តាមកាលបរិច្ឆេទមានរបៀបរះចាត់ការតាមលំដាប់គម្រប់ ៤ ថ្ងៃដូចតទៅនេះ :

១-ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំមមីឆស័ក ព.ស.២៤៩៧ គ.ស.១៩៥៤ជាថ្ងៃសុកមង្គលចូលបុណ្យបញ្ចុះអដ្ឋិធាតុនិងសីមា, នៅវេលារសៀលម៉ោង៥ រៀបភេសជ្ជៈប្រគេនភិក្ខុសង្ឃ សាមណេរឆាន់គ្រប់ព្រះអង្គដែលនិមន្តមកក្នុងកំឡុងបុណ្យនោះគ្រប់រោងទាំង៨ទិស, ពេលម៉ោង៧ យប់ ជួបជុំពុទ្ធបរិស័ទ

ប្រុសស្រីវេរវេនជីវត្ថុនឹងដុំសិលា បុសសីមាប្រគេនដល់ព្រះសង្ឃនិមន្តព្រះសង្ឃចំរើនព្រះបរិត្តប្រស់ទឹកដុំសិលាបុសសីមាគ្រប់កើនទាំង៨ទិស, ម៉ោង៩យប់និមន្តព្រះធម្មកថិកសំដែងធម្មទេសនា ផ្សាយតាមគ្រឿងឧគ្ឃោសនសព្ទ ពណ៌នាអំពីពិធីបញ្ចុះសីមាតាមច្បាប់ព្រះពុទ្ធសាសនាយ៉ាងក្បោះក្បាយ ។

៦– ថ្ងៃសុក្រ ១៤ កើតខែ-ផាំជផែល នៅពេលព្រឹកប្រគេនយាគូ,ពេលត្រង់ប្រគេនភត្តាហារដល់ព្រះសង្ឃគ្រប់ព្រះអង្គ តាមកំណាន់ដែលក្រុមគណកម្មការបានចាត់តម្រូវព្រះសង្ឃឲ្យក្នុងរោងទីមួយៗគ្រប់រោងបុណ្យ,ពេលរសៀលម៉ោង៤ បានប្រជុំពួកគ្រហស្ថនឹងបព្វជិត ជាពុទ្ធបរិស័ទដែលបាននិមន្តអញ្ជើញមកពីទិដិតឆ្ងាយមាន ឯ.ឧ.ឃុត-ឃៀនចៅហ្វាយខេត្តកំពង់ធំ បានអញ្ជើញមកជាអធិបតីក្នុងទីនេះផង បានរៀបចំតាក់តែងក្បួនហែព្រះពុទ្ធរូបព្រមទាំងអដ្ឋិធាតុព្រះសពស្រី-អ៊ុម មេគណខេត្តកំពង់ធំ ចុះពីទីកន្លែងកុដិព្រះសមុហ៍គណ អ៊ុក-ឡេង ចេញទៅប្រទក្សិណវិហារ៣ជុំរួចហើយ បត់បែរចូលទៅកាន់ទីចេតិយធំប្រទក្សិណចេតិយធំ ៣ ជុំហើយទើបហែបត់ចូលទៅដំកល់ក្នុងរោងទីឯបាកំមណ្ឌប ដែលគេបានរៀបចំគ្រឿងសក្ការបូជាទុកនៅទីនោះជាកិត្តិយសស្រាប់, បន្ទាប់ពេលនោះមកគេនិមន្តព្រះរាជាគណៈ ១អង្គសូត្រសុន្ទរកថាបញ្ចេញសំឡេងតាមគ្រឿងឧគ្ឃោសនសព្ទ រៀបរាប់អំពី "ជីវប្បវត្តិ" ព្រះសព នាម ស្រី-អ៊ុម នៅចំពោះមុខព្រះមហាថេរានុត្ថេរៈ ឧបាសក ឧបាសិកា មាន ឯ.ឧ. ចៅហ្វាយខេត្តកំពង់ធំជាប្រធាន ស្ដាប់ដោយសេចក្ដីគោរពស្ងប់ស្ងៀមស្ងាត់ស៊ីងតែមានសន្ដានចិត្តកើតធម្មសង្វេគគោរពទន់ជ្រន់ជ្រាបំពោះដួងវិញ្ញាណក្ខន្ធរបស់ព្រះសព ទាំងមានមុខក្រៀមក្រំគាក់រអួលក្នុងចិត្តស្មើរតែគ្រប់គ្នា, សុន្ទរកថានោះមានសេចក្ដីដូចតទៅនេះ :

(នៅមានត)

---

# ការជ្រួញចិត្តចំពោះពុទ្ធសាសនា



លោក ប៊ូរីស

ប្រទេស អូស្ត្រាលី ធ្លាប់នៅក្នុងអំណាចបក្រកតអង់គ្លេសជាយូរមកហើយ បានជាប្រជាជនក្នុងប្រទេសនេះជាអ្នកកាន់សាសនាយេស៊ូគ្រិស្ត ស្ទើរតែទាំងអស់ហើយឥតអ្នកកាន់ពុទ្ធសាសនាសោះ ។ ទុកជាយ៉ាងនេះក៏វេលាដែលព្រះពុទ្ធសាសនាត្រូវរុងរឿង ស្រាប់តែមានកុលបុត្រ ដែលមានឧបនិស្ស័យនឹងពុទ្ធសា-

សនាបានកើតក្នុងប្រទេសនោះ គឺលោក ម៉ូរិស នេះឯង ដែលជាអ្នកផ្ទុះសទ្ធាដោយខ្លួនឯង ហើយ ដឹកនាំជនជាតិអូស្ត្រាលីយានឲ្យមានសទ្ធាចំពោះពុទ្ធ-សាសនាផងជាច្រើន ។ លោកម៉ូរិស ជាតិអូស្ត្រាលី មានបងប្រុសបួននាក់ ប្អូនស្រីបីនាក់ សុទ្ធតែជាអ្នកកាន់សាសនា កាតូលិកតាមបវេណីពីមាតាបិតាមក ។ បិតាជាអ្នកប្រាជ្ញម្នាក់ខាងសាសនាកាតូលិក មានសៀវភៅផ្នែកខាងលទ្ធិកាតូលិកជាច្រើន ។

កាលលោក ម៉ូរិស មានអាយុ ១២ ឆ្នាំបានសើរើមើលសៀវភៅផ្នែកគ្រិស្តសាសនា អស់វេលាមួយឆ្នាំ ហើយ ស្រាប់តែប្រទះសៀវភៅពុទ្ធសាសនាមួយផ្នែកខាងព្រះសូត្រមានព្រហ្មជាលសូត្រជាដើម លោកក៏ប្រៀបធៀបសេចក្ដីនៃសាសនាទាំងពីរនេះ ឃើញថាសៀវភៅខាងសាសនាយេស៊ូគ្រិស្ត មិនសូវពិតសោះ ហើយមិនឃើញប្រាប់ហេតុផលជាប្រាកដផង; សៀវភៅផ្នែកពុទ្ធសាសនា មានគោលការណ៍ដែលគួរឲ្យជឿជាក់គ្រប់ពាក្យទាំងអស់ ។ ទើបលោកធ្វើទុកក្នុងចិត្តថា នឹងស្វែងរករៀនពុទ្ធសាសនាឲ្យបានប្រាកដ ។ ដល់អាយុ ១៣ ឆ្នាំ លោកបានចូលទៅសិក្សាក្នុងសំណាក់លោកសង្ឃរាជកាតូលិក ។ លោកសង្ឃរាជសួរថាអ្នកណាបង្កើតឯង ? ម៉ូរិស= ម្ដាយឪពុកខ្ញុំបង្កើតខ្ញុំ ។ សង្ឃរាជ = មិនមែនទេ ព្រះម្ចាស់សួគ៌ ទេតើបង្កើតឯងមក ។ ម៉ូរិស = នៅឯណាព្រះនោះ? សង្ឃរាជ = នៅឯស្ថានសួគ៌ ។ ម៉ូរិស= ព្រះនោះធ្លាប់មកស្រុកយើងទេ? សង្ឃរាជ = មិនធ្លាប់មកទេ ។ ម៉ូរិស = បើដូច្នោះម្ដេចក៏បង្កើតខ្ញុំបាន? រឿងនេះជាការមិនពិតសោះឡើយ ។ លោកសង្ឃរាជនោះក៏ខឹងចង់វាយដំប្រំណាក់ តែដោយគ្មានហេតុផលល្មមធ្វើទោសបានឡើយ ។

លោកម៉ូរិស ក៏តាំងខ្លួនជាមនុស្សឯកឯង គ្មានសាសនាកាន់នឹងគេ ។ ដោយហេតុនេះ ម្ដាយមីងរបស់លោកម្នាក់ ជាអ្នកប្រូតិស្តង់ បានបបួលលោកម៉ូរិសឲ្យចូលខាងលទ្ធិប្រូតិស្តង់ដោយពាក្យថាមនុស្សដែលឥតកាន់សាសនាណាមួយសោះនោះមិនល្អទេ ។ លោកម៉ូរិសក៏មិនព្រមចូល, ដល់មានអាយុ ១៤ ឆ្នាំ ទើបដាក់ចិត្តទិនសិប់ក្នុងពុទ្ធសាសនា យ៉ាងមាំដោយខ្លួនឯង ។ ដល់អាយុ ២៨ ឆ្នាំទើបលោកលាមាតាបិតាចេញទៅរៀនពុទ្ធសាសនាឯប្រទេសភូមា (ក្នុង គ.ស. ១៩២៦) លោកបានសិក្សាច្បាប់ពុទ្ធសាសនា ព្រមទាំងអប់រំកម្មដ្ឋានយ៉ាងម៉ឺងម៉ាត់ ។

សព្វថ្ងៃលោកធ្វើការក្នុងពុទ្ធសមាគមភូមា ជាអ្នកផ្ទៀងផ្ទាត់, រៀបរៀងកិច្ចការខាងពុទ្ធសាសនា ព្រមទាំងប្រមូលដំណឹងខាងសាសនាពីបរទេសយកទៅចុះក្នុងកាសែតក្នុងទស្សនាវដ្ដី ហើយផ្សាយដំណឹងពុទ្ធសាសនាដោយកាសែតនិងទស្សនាវដ្ដី បញ្ជូនទៅប្រទេសអូស្ត្រាលី ដកចែកអ្នកអូស្ត្រាលីយាន

ជឿកាន់ព្រះពុទ្ធសាសនាដោយច្រើន ។ ពេលយប់ លោកបង្រៀនភាសាអង់គ្លេស ដល់កូនអ្នកស្រុកជាច្រើនរូប ដោយឥតយកថ្លៃឈ្នួល ព្រមទាំងបង្រៀនសមណនិស្សិតជាតិខ្មែរ៦អង្គមានលោកគ្រូព្រះមហាអ៊ុង-មាន (បន្ទវណ្ណ:)ជាដើម ដែលទៅនៅសិក្សាឯប្រទេសភូមានោះផង ។ លោកម៉ូរិសជាអ្នកល្បីល្បាញខាងការបង្រៀនភាសាអង់គ្លេស ព្រោះលោកធ្លាប់សិក្សាក្នុងសាលាតរិជ្ជាជាន់ខ្ពស់ ។

សមណនិស្សិតខ្មែរយើង ដែលនៅប្រទេសភូមាបានសរសេរសេចក្ដីដូចខាងលើនេះផ្ញើមក ព្រមទាំងឲ្យដំណឹងមុនថា: លោកម៉ូរិសនឹងចេញដំណើរពីប្រទេសភូមា មកពីថ្ងៃ ២៩-៨-៥៤ ចូលមកប្រទេសកូសាំងស៊ីន ដល់ថ្ងៃ ១៥-៩-៥៤ នឹងមកដល់ក្រុងភ្នំពេញ ដើម្បីទស្សនារបៀបសិក្សា និងរបៀបប្រតិបត្តិព្រះពុទ្ធសាសនាក្នុងប្រទេសកូសាំងស៊ីន នឹងប្រទេសកម្ពុជា ដល់ថ្ងៃ ៣០-៩-៥៤ នឹងចូលទៅដល់ប្រទេសភូមាវិញ ដើម្បីកាន់ការក្នុងជំណែងដដែល ។

## ប្រវត្តិក្មេងកំព្រា

(តពីលេខ ៥ មក)

ជាតិអ៊ីរុប មានជាន់ពីរ មានគាគារដូចជាអណ្ដែតចេញពីដីរវៃនក្រុងជាតិ, បើសិនជាមានអ្នកឈរមើលពីចម្ងាយ



នៅទីបំផុតនៃជាន់ គេពុំបានឃើញដំបូលប្រក់ក្បឿង ដូចគេហស្ថានធម្មតានោះទេ; ព្រោះគេបានចាត់ទុកទីនោះជារមណីយដ្ឋានមួយ សម្រាប់ក្រសាលក្នុងពេលរាត្រី ខ្ញុំពុំបានរៀបរាប់ឲ្យសព្វគ្រប់ទេ ចំពោះគេហស្ថានដ៏វិសេសនេះ, សូមជំរាបពីជនអ្នកនៅក្នុងគេហស្ថាននោះវិញ ។

នៅគេហស្ថានដ៏ធំទូលាយស្អាតនេះ គេពិនិត្យទៅឃើញមានមនុស្ស៥នាក់ គឺ លោកមហាពាណិជ្ជជនសិរី, នារីជនសាវៀន, នាយសំណាង អ្នកបើករថយន្ត នឹងអ្នកបំរើស្រីម្នាក់, មានម្នាក់ទៀតជាអ្នកសំអាតសួននឹងទំលានជុំវិញគេហស្ថាន តែអ្នកបំរើនេះមកធ្វើការតែក្នុងពេលថ្ងៃ ដល់ពេលយប់ត្រឡប់ទៅកាន់លំនៅរបស់ខ្លួនវិញ ។

នៅប្រែបន្ទប់ទទួលភ្ញៀវ នៃគេហស្ថានលោកមហាពាណិជ្ជ មានបន្ទប់តូចមួយ ក្នុងបន្ទប់នោះមានគ្រែ ១ តុ ១ នឹងទូតូច ១ មានបំពង់ទឹកមួយនៅទី

នោះ សម្រាប់លុបលាងខ្លួនក្នុងពេលយប់ នេះជាសេចក្ដីសុខទី ១ ដែលសំណាងទើបនឹងប្រទះ; សំណាងគេងហើយឬ ផ្ទះរបស់ឪពុកអ្នក, លោកគ្រូចៅអធិការ នឹងលោកជន្លៅប្រសើរ ព្រមទាំងបុត្រីគាត់ សំណាងមិនមែនជាជនដែលគេអាចរាប់បានថា ជាមនុស្សបែបណាបានឡើយ ក្នុងពេលដែលសំណាងជួបសេចក្ដីសុខដ៏អស្ចារ្យនេះ ; តែខ្ញុំសូមជំរាបលោកអ្នកអានថា សំណាងជាខេមរបុត្តមួយរូប ដែលបានសិក្សាវិជ្ជាផ្លូវសាសនាដោយមុតមាំ នឹងផ្លូវលោកកំពុងបំពេញសព្វថ្ងៃ បើដូច្នេះសូមអស់លោកចាំដឹងថាសំណាងជាមនុស្សបែបណា ក្នុងទំព័រទៅខាងមុខទៀតចុះ ។ ពល់តែថ្ងៃសៅរ៍ នឹង អាទិត្យ, នៅក្នុងសាស្ត្រាចារ្យមួយអង្គ ក្នុងវត្តលង្កាគេឃើញសំណាងទៅកាន់កន្លែងលោក; ប្រហែលជាសំណាងបន្តការសិក្សាផ្នែកសាសនាតទៅទៀតក៏ពុំដឹង? ដោយគ្មានជនណាមួយដឹងហេតុៈខុះច្បាស់សោះ ។ ក្នុង ៣ ឆ្នាំកន្លងផុតមក សំណាងបានប្រឡងជាប់ប្រកាសនីយប័ត្រមានពិន្ទុជាន់ឯក បានបន្តវិជ្ជានៅវិទ្យាល័យស៊ីសុវត្ថិទៀត ។ នៅឱកាសចូលឆ្នាំខ្មែរ ជាពេលវិស្សមកាលនៃសិស្សទាំងឡាយ សំណាងក៏ត្រូវតែធ្វើដំណើរទៅកាន់គេហស្ថានឪពុកចិញ្ចឹមអ្នកដែរ ។

ក្នុងគេហស្ថានលោកមហាពាណិជ្ជ មនុស្សទាំងឡាយចូលកាន់ដំណេកស្ងាត់អស់ ពន្លឺភ្លើងក្នុងគេហស្ថានក៏រលត់ នៅសល់តែបន្ទប់សំណាងមួយប៉ុណ្ណោះទេដែលពុំទាន់អស់ពន្លឺភ្លើង ។ សំណាងកំពុងតែរៀបចំទុកដាក់សំលៀកបំពាក់របស់ខ្លួន នឹងសៀវភៅដែលត្រូវយកទៅសិក្សាក្នុងឱកាសវិស្សមកាល ទោះបីអ្នករៀបចំរួចជាស្រេចក៏ដោយ ក៏អ្នកនៅតែមិនទាន់ចូលនិទ្រា ដោយរាត្រីមិនបើកឱកាសឲ្យអ្នក, អ្នកចេះតែចេញ ចូលដូចជាជនដែលមានកង្វល់ជាប់ក្នុងចិត្ត; អ្នកចូលសម្ងំក្នុងបន្ទប់ តែភ្លើងក្នុងបន្ទប់នៅភ្លឺ ។ បន្តិចសូរដៃយ៉ាងស្រាលគោះទ្វារអ្នក សំណាងស្ទុះក្រោកភ្លាមដោយសេចក្ដីឆ្ងល់ បានបើកភ្លាម — យី! អ្នកអូនអញ្ជើញមកបន្ទប់ខ្ញុំមានការអ្វី ក្នុងរាត្រីស្ងាត់យ៉ាងនេះ—សំណាង! បងឯងអង្គុយចុះ រូបបងនឹងរូបខ្ញុំមិនមែនមានសភាពខុសគ្នាប៉ុន្មានទេ ខ្ញុំមកនេះដើម្បីនឹងជូនដំណើរបង ដែលត្រូវត្រឡប់ទៅផ្ទះឪពុករបស់បងវិញ, អត់ទោសអ្នកអូនរាត្រីនេះក្រែងមិនគួរបំពោះដំណើរអ្នកនាងមកកាន់បន្ទប់ខ្ញុំ ចុះបើយើងចាំពេលព្រឹកទៅជាការគួរឬ? ខ្ញុំដូចជាចេះតែបារម្ភក្រែងមានការណ៍អ្វីមួយដែលខ្ញុំ នឹងអ្នកនាងមើលមិនឃើញនៅពេលមុខ— ទេបងឯងកុំនិយាយយ៉ាងនេះ ខ្ញុំមិនមែនយកទុក្ខមកជូនបងទេ ។ បើសិនជាអ្នកអូនមិនយកទុក្ខមកឲ្យខ្ញុំ ហេតុម្ដេចក៏អ្នកអូនមកកន្លែងខ្ញុំក្នុងរាត្រីស្ងាត់ដូចនេះ? ណ្ហើយបង! កុំមានប្រសាសន៍ឲ្យវែងតទៅទៀត ខ្ញុំសូមឱកាសបន្ទូនជា ៣០ នាទី

(នៅមានត)

# ដំណឹងពីក្រុងម៉ានីល

តាមកាសែតយៀតណាមពត៌មាន

មានស្ត្រីចាស់ម្នាក់នៅ ហ្វីលីពីន ទទួលមរណភាពដោយចាស់ជរា អាយុ១៣៩ឆ្នាំ នៅទីលំនៅរបស់គាត់ ទីក្រុងបូអាង ក្នុងខេត្ត ឡាអ៊ុយនីញ៉ុង ( La union ) ។

ស្ត្រីនោះនាមឈ្មោះ អ្នកស្រី ហ្វ្រង់ស៊ីស្កា ម៉ាបង់គា វីយូដា ដឺ យង់តានូស ( **Francisca Mabunga viuda de Gontanos** ) ហើយបានរស់នៅក្នុងត្រកូល ៥ត ដែលរួមជនក្នុងគ្រួសារទាំងអស់មាន ៥០០នាក់ គឺតាំង កូន-ចៅ-ចៅទួត-ចៅលួត-ចៅលា ។

# អក្សរសាស្ត្រខ្មែរឈានជើងដើរហើយ

ដោយសេចក្តីប្រឹងប្រែងរបស់ពួករដ្ឋាភិបាល ទីង ឯកឧត្តម ក៉យ-ល្នុត ជានាយកមន្ទីរប្រៃសទីយ៍ ឥឡូវនេះគេឃើញអាណត្តិប្រៃសទីយ៍ប្រទេសកម្ពុជា បានចេញប្រើការជាអក្សរខ្មែរហើយ ; គេនឹកស្មានថាក្រុមប្រៃសទីយ៍នឹងទូរគមនាគមន៍ មានការទាក់ទងត្រូវប្រើអក្សរជាតិបរទេសជាយ៉ាងស្មុគស្មាញបំផុត មិនសមនឹងផ្លាស់ប្រែមករកអក្សរខ្មែរយើងវិញបានដោយងាយឡើយ ។ ពេលនេះស្រាប់តែឃើញអក្សរជាតិយើងបានអណ្តែតតាមផ្លូវគមនាគមន៍ជាយ៉ាងឆ្ងាយស្រឡាល គួរអស្ចារ្យជាទីបំផុត ។

យើងខ្ញុំទាំងអស់គ្នាជាក្រុមអភិបាលនឹងជាទីប្រឹក្សាសមាគមមិត្តសាលាបាលី សូមស្ងើចសរសើរនឹងសូមលើកដៃប្រទូលចំពោះករណីយកិច្ចជាទីគាប់ចិត្តនេះ ។

យើងខ្ញុំមានសេចក្តីសង្ឃឹមតទៅទៀតថា ក្រសួងដទៃដែលមានការមិនបានជំពាក់ស្មុគស្មាញជាងក្រសួងប្រៃសទីយ៍នេះប៉ុន្មាននោះ មុខជានឹងបានឃើញអក្សរសាស្ត្រខ្មែរយើងបានអណ្តែតឡើងកាន់ផ្លូវការដោយឆាប់រហ័សជាពុំខាន ។

ជ.យោ។ អក្សរសាស្ត្រខ្មែរ

ទីចាត់ការនៅវត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ

បណ្ណាគារ ហ្លួត-ហៀម